# 20 ការបង្ការ និងការកាត់បន្ថយគ្រោះថ្នាក់ពីសារធាតុពុល

**នៅក្នុងជំពូកនេះ :** **ទំព័រ**


ការចៀសវាង និងការគ្រប់គ្រងការបំពុល . . . . . . . . . . 450
យើងអាចបង្ខំឲ្យក្រុមហ៊ុនធ្វើការសម្អាត . . . . . . . . . . 451
ការចំណាយដែលមើលមិនឃើញ និងអ្នកដែលបង់ថ្លៃទាំងនេះ . . . . . . . . . . 452
ការបំពុលខ្យល់ . . . . . . . . . . 454
ការតាមដានការបំពុលខ្យល់ . . . . . . . . . . 455
សាច់រឿង : មធ្យោបាយកងពលធុងទឹកនៃក្រុម "ការងារមូលដ្ឋាន" . . . . . . . . . . 456
ផលិតកម្មស្អាត . . . . . . . . . . 458
ពាណិជ្ជកម្មស្អាតតូចតាច . . . . . . . . . . 459
សាច់រឿង : ផលិតកម្មស្អាតនៅក្នុងរោងចក្រកែច្នៃស្បែក . . . . . . . . . . 461
សាច់រឿង : បទពិសោធន៍នៃផលិតកម្មស្អាត . . . . . . . . . . 462
ការចោលកាកសំណល់ពុលដោយគ្មានសុវត្ថិភាព . . . . . . . . . . 463
សាច់រឿង : គម្រោងស្តុកទុកកាកសំណល់នៃបណ្តាប្រទេសអាហ្វ្រិក . . . . . . . . . . 463
ពាណិជ្ជកម្មកាកសំណល់ពុល . . . . . . . . . . 465
សាច់រឿង : យកកាកសំណល់ពុលរបស់អ្នក ទៅផ្ទះវិញទៅ . . . . . . . . . . 465
សាច់រឿង : កីឡាបេសបលដើម្បីសុខភាព . . . . . . . . . . 466
កិច្ចព្រមព្រៀងអន្តរជាតិស្តីអំពីការបោះចោលកាកសំណល់ពុល . . . . . . . . . . 467
សកម្មភាព : ល្បែងពស់ និងជណ្តើរ . . . . . . . . . . 468

# ការបង្ការ និងការកាត់បន្ថយគ្រោះថ្នាក់ពីសារធាតុពុល




ក្នុងពេលដែលយើងស្វែងយល់កាន់តែច្រើនអំពីផលប៉ះពាល់ដ៏គ្រោះថ្នាក់នៃសារធាតុគីមីពុលមកលើសុខភាព និងបរិស្ថានរបស់យើង មនុស្សកាន់តែច្រើនកំពុងរៀបចំសកម្មភាពដើម្បីបង្ការគ្រោះថ្នាក់ និងស្វែងរកមធ្យោបាយដែលមិនសូវប៉ះពាល់សុខភាពនិងមានចិរភាពក្នុងការផលិតវត្ថុផ្សេងៗ។

ម្ចាស់ពាណិជ្ជកម្ម អ្នកដឹកនាំរដ្ឋាភិបាល និងអ្នកវិទ្យាសាស្ត្រមួយចំនួន ព្យាយាមលើកយកហេតុផលដើម្បីការពារគ្រោះថ្នាក់ពីសារធាតុពុលថា ការប្រឈមគ្រោះថ្នាក់ជាក់លាក់មួយចំនួនគឺអាចទទួលយកបានដោយសារតម្លៃនៃការអភិវឌ្ឍន៍( យើងអាចមានអគ្គិសនី ការថែទាំផ្នែកវេជ្ជសាស្ត្រ ការដឹកជញ្ជូន កុំព្យូទ័រ ។ល។)។ ប៉ុន្តែអ្វីដែលពួកគេមិនបានប្រាប់យើងគឺ យើងអាចទទួលបានផលប្រយោជន៍ទាំងនេះតាមមធ្យោបាយមួយចំនួនដែលមានសុវត្ថិភាពប្រសើរសម្រាប់ប្រជាជននិងបរិស្ថាន( មើលទំព័458 )។ ជាជាងការទទួលយកការប្រឈមនឹងគ្រោះថ្នាក់ដែលមិនចាំបាច់ យើងអាចជ្រើសរើសផលិតកម្មអាហារ ទំនិញរោងចក្រ និងថាមពលដែលមានសុវត្ថិភាពប្រសើរ ខណៈនៅតែបង្ការភាពកខ្វក់ដោយសារសារធាតុពុលបានយ៉ាងច្រើនតាមដែលអាចធ្វើបាន។

# ការចៀសវាង និងការគ្រប់គ្រងការបំពុល

ការបង្ការការប្រឈមនឹងភាពកខ្វក់ដោយសារសារធាតុពុល ចាប់ផ្តើមឡើងពីគោលការណ៍ប្រុងប្រយ័ត្ន(មើលទំព័រ32)ដែលគិតអំពីគ្រោះថ្នាក់ផ្សេងៗមុននឹងធ្វើសកម្មភាពមួយឬប្រើប្រាស់ ផលិតផលអ្វីមួយ ថាតើវាអាចបង្កគ្រោះថ្នាក់អ្វីខ្លះ។ ខណៈដែលយើងអាចធ្វើការសម្រេចចិត្តផ្ទាល់ខ្លួន និងការសម្រេចចិត្តជាសហគមន៍ដើម្បីចៀសវាងគ្រោះថ្នាក់ឲ្យបានច្រើនបំផុតតាមដែលអាច, យើងក៏ចាំបាច់ត្រូវតែទាមទារម្ចាស់ពាណិជ្ជកម្ម និងរដ្ឋាភិបាលរបស់យើង ឲ្យយកសុខភាពយូរអង្វែងសម្រាប់មនុស្សទាំងអស់(មិនថាមានឬក្រ) និងបរិស្ថានធ្វើជាចំណុចសំខាន់ជាងផលប្រយោជន៍របស់កម្មករនិងសាជីវកម្ម។

អ្វីៗជាច្រើនដែលយើងធ្វើជារៀងរាល់ថ្ងៃ ប៉ះពាល់លើរបៀបដែលយើងនិងអ្នកដទៃប្រឈមនឹងសារធាតុពុល។ មានការប្រឈមប្រចាំថ្ងៃខ្លះៗដែលយើងមិនអាចគ្រប់គ្រងបានដោយការសម្រេចផ្ទាល់ខ្លួនឡើយ។ ប៉ុន្តែមានការប្រឈមមួយចំនួនដែលយើងអាចដាក់កម្រិតវាបាន តាមរយៈការសម្រេចចិត្តដែលជួយរក្សាខ្លួនយើង គ្រួសារយើង និងសហគមន៍យើង ឲ្យមានសុវត្ថិភាពនិងសុខភាពប្រសើរ។ ការសម្រេចផ្ទាល់ខ្លួនច្រើនតែឈានដល់សកម្មភាពសហគមន៍ ព្រោះយើងមើលឃើញថាមនុស្សតែម្នាក់មិនអាចគ្រប់គ្រងលើគ្រោះថ្នាក់ពីសារធាតុពុលដែលយើងកំពុងប្រឈមឡើយ។



ដើម្បីបញ្ឈប់គ្រោះថ្នាក់ដែលបង្កឡើងដោយសារធាតុពុល យើងត្រូវតែ :

**អប់រំខ្លួនយើង។** ស្វែងយល់និងបង្រៀនអ្នកដទៃអំពីអ្វីដែលហៅថាសារធាតុពុល និងថាតើសារធាតុពុលបង្កគ្រោះថ្នាក់យ៉ាងដូចម្តេច។ អានសៀវភៅនេះ, ជជែកជាមួយប្រជាជន, និងរៀនពីអង្គការផ្សេងៗដែលផ្តល់ព័ត៌មានអំពីសារធាតុពុល។ សាលារៀន មណ្ឌលសុខភាព កន្លែងធ្វើការ មណ្ឌលក្នុងសហគមន៍ និងផ្ទះរបស់យើង សុទ្ធតែអាចជាកន្លែងសម្រាប់អប់រំសហគមន៍អំពីសារធាតុពុលនិងសុខភាព។ (សម្រាប់សកម្មភាពនៃការពិភាក្សាក្នុងសហគមន៍អំពីសារធាតុពុល សូមមើលទំព័រ468)។

**ស្វែងរកប្រភពនៃការប្រឈមនឹងសារធាតុពុល**នៅក្នុងផ្ទះរបស់យើង ប្រភពទឹក ផ្ទះសម្បែងអ្នកជិតខាង កន្លែងធ្វើការ សាលារៀន និងភូមិភាគ។ ដើម្បីវាយតម្លៃអំពីផលប៉ះពាល់នៃភាពកខ្វក់ដោយសារសារធាតុពុលនៅក្នុងសហគមន៍របស់អ្នក ចូរធ្វើការដើរពិនិត្យមើលសំរាម(មើលទំព័រ391), ធ្វើការស្ទង់មតិផ្នែកសុខភាព (មើលទំព័រ500), ឬបង្កើតក្រុមមួយដើម្បីតាមដានការបំពុល(មើលទំព័រ456)។

**ចៀសវាងសារធាតុពុលគ្រប់ប្រភេទតាមដែលអាច។** ស្ថិតនៅឲ្យឆ្ងាយពីប្រភពសារធាតុពុលដែលអ្នកបានដឹង។ កាត់បន្ថយការប្រើប្រាស់ផលិតផលពុល ដោយការស្វែងរកមធ្យោបាយជំនួសសម្រាប់ផលិតផលសម្អាត(មើលទំព័រ373) និងដោយការគ្រប់គ្រងសត្វល្អិតចង្រៃក្នុងទម្រង់ដែលគ្មានការបំពុល(មើលទំព័រ296 ទៅ301 និង366)។ គ្រប់គ្រងសារធាតុពុលដោយការរៀបចំកម្មវិធីកាកសំណល់រឹងក្នុងសហគមន៍(មើលទំព័រ75) និងដោយការធ្វើការងារដើម្បីបណ្តេញពាណិជ្ជកម្មឬសកម្មភាពដែលមានការបំពុល ឲ្យទៅឆ្ងាយពីកន្លែងដាំដំណាំ និងទីសាធារណៈដូចជាសួនច្បារជាដើម។ ធ្វើឲ្យប្រាកដថា សារធាតុពុលមិនត្រូវបានរក្សាទុកប្រើប្រាស់ ឬបញ្ចេញទៅក្នុងឬទៅក្បែរកន្លែងដែលប្រជាជនរស់នៅឡើយ។ ធ្វើឲ្យប្រាកដថា កុមារ មនុស្សចាស់ អ្នកជំងឺ និងស្ត្រីមានផ្ទៃពោះឬស្ត្រីកំពុងបំបៅដោះកូន មិនមានការប្រឈមនឹងសារធាតុពុលទេ។

យើងមិនអាចជ្រើសរើសខ្យល់ដែលយើងដកដង្ហើម ទឹកដែលយើងផឹក ឬសម្ភារៈដែលនិយោជករបស់យើងឲ្យយើងធ្វើការទេ, ហើយជាញឹកញាប់យើងមិនអាចដឹងថាតើយើងប្រឈមនឹងអ្វីខ្លះដែលមាននៅក្នុងរបស់ដែលយើងបរិភោគឬផលិតផលដែលយើងប្រើប្រាស់ទេ។ ដោយមូលហេតុនេះហើយ យើងចាំបាច់រៀបចំសកម្មភាពដើម្បីទាមទារក្រុមហ៊ុនពាណិជ្ជកម្មនិងរដ្ឋាភិបាលឲ្យកាត់បន្ថយការប្រើប្រាស់សារធាតុពុល និងការគំរាមកំហែងនៃសារធាតុពុល។ មនុស្សជាច្រើនដែលធ្វើការជាមួយគ្នានៅក្នុងជំនឿរួមមួយដែលថាអ្វីមួយមានគ្រោះថ្នាក់យ៉ាងខ្លាំង មានអំណាចនឹងធ្វើការផ្លាស់ប្តូរ។

# យើងអាចបង្ខំឲ្យក្រុមហ៊ុនធ្វើការសម្អាត




ការទទួលខុសត្រូវលើភាពកខ្វក់ដោយសារសារធាតុពុលភាគច្រើនស្ថិតនៅលើឧស្សាហកម្មដែលមានការបំពុល ដូចជារោងចក្រថាមពល រោងចក្រផលិតផល ឬឧស្សាហកម្មចម្រាញ់ប្រេងនិងរ៉ែ, ខណៈដែលបន្ទុកនៃការរស់នៅជាមួយភាពកខ្វក់ដោយសារសារធាតុពុល និងការសម្អាតវា ជាទូទៅត្រូវធ្លាក់ទៅលើប្រជាជនដែលរស់នៅក្បែរកន្លែងបញ្ហានោះ។ សហគមន៍ខ្លះបានទទួលជោគជ័យក្នុងការបង្វែរការទទួលខុសត្រូវទៅឲ្យឧស្សាហកម្មវិញ និងបានបង្ហាញថាឧស្សាហកម្មឬក្រុមហ៊ុនជាក់លាក់មួយជាអ្នកបង្កើតបញ្ហា និងគួរតែសម្អាតវា និងតាំងចិត្តប្រកាន់ខ្ជាប់នូវការអនុវត្តប្រកបដោយសុវត្ថិភាព។ (ចំពោះសាច់រឿងនៃសហគមន៍ដែលបានបង្ខំក្រុមហ៊ុនឲ្យសម្អាតភាពកខ្វក់ សូមមើលទំព័រ344, 465, 483, និង521)។

### ដាក់សម្ពាធលើរដ្ឋាភិបាលឲ្យផ្តល់ស្តង់ដារសុវត្ថិភាពល្អប្រសើរ

ការការពារប្រជាជនពីការបំពុល គឺជាការទទួលខុសត្រូវរបស់រដ្ឋាភិបាល។ ប៉ុន្តែសាជីវកម្មនិងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិដ៏មានឥទ្ធិពល បានដាក់សម្ពាធលើរដ្ឋាភិបាលឲ្យបំបាត់ចោលឬព្រងើយកន្តើយចំពោះច្បាប់នៃការប្រើប្រាស់សារធាតុពុល។ ដើម្បីបង្ខំឲ្យរដ្ឋាភិបាលបង្កើតនិងអនុវត្តច្បាប់ដែលការពារប្រជាជន ចាំបាច់ត្រូវតែមានសម្ពាធយ៉ាងខ្លាំងពីសហគមន៍ទាំងឡាយ ជាពិសេសក្នុងប្រទេសដែលព្យាយាមទាក់ទាញពាណិជ្ជកម្មឲ្យមកវិនិយោគក្នុងប្រទេសរបស់ខ្លួន។ ប៉ុន្តែយុទ្ធនាការតាមសហគមន៍ អាចបង្ខំឲ្យមានការផ្លាស់ប្តូរផ្លូវច្បាប់ (មើលទំព័រ417, 465, 466, 473 និង480) ក៏ដូចជាឲ្យប្រើប្រាស់ច្បាប់បរិស្ថានដែលមានស្រាប់(មើលសេចក្តីបន្ថែម ខ)។

### ដាក់សម្ពាធឲ្យមានការផ្លាស់ប្តូរលើរបៀបបង្កើតផលិតផល

ឧស្សាហកម្មជាច្រើនបានបង្កើតវិធីផ្សេងៗដែលមានចិរភាពជាង និងមិនសូវបំផ្លាញសុខភាពមនុស្សនិងបរិស្ថាន ដើម្បីជំនួសសារធាតុគីមីពុល និងមធ្យោបាយផលិតកម្ម។ មើលទំព័រ458 សម្រាប់ព័ត៌មានបន្ថែមអំពីមធ្យោបាយផលិតកម្មស្អាត និងវិធីដាក់សម្ពាធលើក្រុមហ៊ុនពាណិជ្ជកម្មឲ្យសម្របតាម។

### ផ្លាស់ប្តូរលំនាំនៃការប្រើប្រាស់

នៅចុងបញ្ចប់ ពួកអ្នកមានប្រើប្រាស់របស់ច្រើនពេក។ ការប្រើប្រាស់និងកាកសំណល់តិចតួច ដោយប្រើល្មមតែគ្រប់គ្រាន់ប៉ុន្តែមិនលើសលុប គឺជាផ្នែកដ៏ធំមួយនៃដំណោះស្រាយ។

# ការចំណាយដែលមើលមិនឃើញ និងអ្នកដែលបង់ថ្លៃទាំងនេះ

ឧស្សាហកម្មជាច្រើនដែលផលិតនិងប្រើប្រាស់សម្ភារៈពុល ប្រាប់ប្រជាជនថាសម្ភារៈនិងផលិតផលទាំងនោះមានសុវត្ថិភាពនិងជារបស់ចាំបាច់។ ប៉ុន្តែវាមិនមែនជាការពិតទេ។ សារធាតុគីមីនិងផលិតផលជាច្រើនដែលប្រជាជនធ្លាប់គិតថាមានសុវត្ថិភាពនិងជារបស់ចាំបាច់ ដូចជាប្លាស្ទិកPVC ប្រេងសាំងមានជាតិសំណ ឬថ្នាំសម្លាប់សត្វល្អិត ឥឡូវនេះត្រូវបានដឹងថាបង្កគ្រោះថ្នាក់យ៉ាងខ្លាំង។ ហើយសារធាតុពុលជាច្រើនអាចត្រូវបានជំនួសដោយអ្វីផ្សេងដែលមានសុវត្ថិភាពជាង ប្រសិនបើឧស្សាហកម្មគ្រាន់តែស្វែងរកវានិងប្រើប្រាស់វាប៉ុណ្ណោះ។

ការអភិវឌ្ឍន៍ផ្នែកឧស្សាហកម្ម មាន "ការចំណាយដែលមើលមិនឃើញ" ជាច្រើន ក្នុងទម្រង់ជាការបំផ្លាញបរិស្ថាន និងបញ្ហាសុខភាពរបស់មនុស្ស។ ការចំណាយដែលមើលមិនឃើញទាំងនេះ ជាទូទៅត្រូវបាន "បង់ថ្លៃ" ដោយប្រជាជនដែលត្រូវរស់នៅជាមួយគ្រោះថ្នាក់ពីសារធាតុពុល គឺមិនមែនដោយឧស្សាហកម្មដែលបង្កគ្រោះថ្នាក់នោះទេ។ វិធីមួយដែលឧស្សាហកម្មអាចការពារនិងបង្កើនប្រាក់ចំណូលរបស់ខ្លួន គឺការកាត់ផ្តាច់ការចំណាយដែលមើលមិនឃើញទាំងនេះ ចេញពីក្រុមហ៊ុនដែលធ្វើសកម្មភាពរាលដាលសារធាតុពុល។ ជាញឹកញាប់ ប្រាក់ចំណូលទាំងនេះមានទំហំធំណាស់ គឺអាចគ្រប់គ្រាន់នឹងគាំទ្រនូវការអនុវត្តប្រកបដោយសុវត្ថិភាព ព្រមទាំងការការពារសុខភាពប្រជាជន។

ជាទូទៅប្រជាជនដែលរងគ្រោះបំផុតពីការបំពុលរបស់ឧស្សាហកម្ម គឺកម្មករនៅក្នុងឧស្សាហកម្មនោះ។ អ្នកដែលរងគ្រោះផ្សេងទៀត គឺអ្នកដែលរស់នៅក្បែរៗ និងមិនអាចផ្លាស់ទីលំនៅទៅកន្លែងដែលមិនសូវពុលបាន។ បញ្ហាសុខភាពជាច្រើនពីសារធាតុពុល គឺមិនអាចព្យាបាលសះស្បើយទេ(មើលជំពូក16)។ ដូច្នេះហើយ ទោះបីអ្នកខ្លះអាចចំណាយលើការព្យាបាលថ្លៃៗក៏ដោយ(ហើយពួកយើងភាគច្រើនមិនអាច) ជារឿយៗគ្រោះថ្នាក់មកលើសុខភាពយើង គឺស្ថិតនៅជាអចិន្ត្រៃយ៍។ ដំណោះស្រាយពិតប្រាកដគឺត្រូវហាមឃាត់ការប្រើប្រាស់សម្ភារៈដែលពុលយ៉ាងខ្លាំង និងគ្រប់គ្រងយ៉ាងតឹងរឹងលើការប្រើប្រាស់សារធាតុពុលដែលចាំបាច់ និងមិនមានមធ្យោបាយជំនួសដែលមានសុវត្ថិភាពជាង។




## វដ្តនៃផលិតកម្មនិងកាកសំណល់ពុល

ទោះបីឧស្សាហកម្មទទួលខុសត្រូវលើការផលិតនិងប្រើប្រាស់សារធាតុគីមីពុលនិងកាកសំណល់ពុលក៏ដោយ យើងគ្រប់គ្នា មិនថារស់នៅក្នុងភូមិតូចមួយឬនៅទីក្រុងធំទេ សុទ្ធតែរងផលប៉ះពាល់ពីវដ្តសកលនៃផលិតកម្ម និងកាកសំណល់។ មិនថាវាជាថង់ប្លាស្ទិកដែលត្រូវបានប្រើប្រាស់ដោយមនុស្សទូទាំងពិភពលោក(មើលទំព័រ 389) ឬវាជាកាកសំណល់ពុលនិងមធ្យោបាយផលិតកម្មដែលត្រូវបានផលិតជាកុំព្យូទ័រ រថយន្ត ឬទូរស័ព្ទទេ, យើងគ្រប់គ្នាសុទ្ធតែមានទំនាក់ទំនងជាមួយវដ្តសកលមួយនៃការផលិតសារធាតុពុលនិងកាកសំណល់ពុល។

**ការផលិតអគ្គិសនី - និងកាកសំណល់ពុល**




**ប្រជាជនរងផលប៉ះពាល់ពីគ្រប់ជំហានទាំងអស់នៃវដ្តផលិតកម្មនិងកាកសំណល់។ ហើយនៅជំហាននីមួយៗ ប្រជាជនអាចធ្វើការដើម្បីបង្ការនិងកាត់បន្ថយគ្រោះថ្នាក់។**

# ប្រភពញឹកញាប់មួយចំនួននៃការបំពុលពីឧស្សាហកម្ម

**រោងចក្រស្លប្រេងកាត និងរោងចក្រថាមពលអគ្គិសនី** បំពុលដល់ខ្យល់ ទឹក និងដី ដោយសារសារធាតុគីមីនិងលោហៈធ្ងន់។សម្រាប់ព័ត៌មានបន្ថែមអំពីរោងចក្រស្លប្រេងកាត សូមមើលទំព័រ513។

**ចង្រ្កានរំលាយ** បញ្ចេញលោហៈធ្ងន់ ដូចជាបារតនិងសំណ(មើលទំព័រ338និង357) និងសារធាតុពុល ដូចជាឌីអុកសាំង(មើលទំព័រ341)។

**រោងចក្រ**គ្រប់ប្រភេទសុទ្ធតែអាចបង្កការបំពុល ប៉ុន្តែគេអាចកែលម្អសុវត្ថិភាពរបស់ខ្លួនដោយប្រើប្រាស់មធ្យោបាយផលិតកម្មស្អាត(មើលទំព័រ458)។

**រណ្តៅកាកសំណល់ឧស្សាហកម្ម** ធ្លាយសារធាតុគីមីជ្រាបទៅក្នុងដីនិងទឹកក្រោមដី បណ្តាលឲ្យមានបញ្ហាសុខភាពធ្ងន់ធ្ងររយៈពេលយូរឆ្នាំ។

**ឡដុតសំរាម**បញ្ចេញសារធាតុគីមីពុលទៅក្នុងខ្យល់ ទឹក និងដី(មើលទំព័រ423)។

**ឧស្សាហកម្មទ្រង់ទ្រាយតូច** ដូចជារោងចក្រកែច្នៃស្បែក រោងចក្រស្រោបលោហៈ រោងចក្រកាត់ដេរ និងរោងចក្រថ្មពិល អាចបង្កការបំពុលនិងបញ្ហាសុខភាពធ្ងន់ធ្ងរទាំងចំពោះកម្មករនិងប្រជាជនរស់នៅក្បែរ(មើលទំព័រ459ទៅ464)។

**មូលដ្ឋានយោធា និងតំបន់សង្គ្រាម** បង្កការបំពុលខ្លាំងក្រៃលែង ចាប់ពីការភាយកាំរស្មី ដល់ឌីអុកសាំង, និងបន្សល់នូវកាកសំណល់គ្រោះថ្នាក់ដែលអាចស្ថិតនៅជាច្រើនជំនាន់ក្រោយៗទៀត។

# ការបំពុលខ្យល់

ខ្យល់ត្រូវបានបំពុលនៅពេលវាប៉ះពាល់នឹងភាពកខ្វក់នៃឧស្ម័នពុល និងភាគល្អិតតូចៗ។ ការបំពុលខ្យល់ភាគច្រើនត្រូវបានបង្កឡើងដោយការដុត**ឥន្ធនៈហ្វូស៊ីល**( ប្រេង ធ្យូង ម៉ាស៊ូត សាំង ) ដើម្បីដំណើរការម៉ាស៊ីនរោងចក្រ និងរោងចក្រថាមពល( មើលទំព័រ526 )។ ខ្យល់និងភ្លៀងអាចនាំយកការបំពុលខ្យល់ទៅកាន់កន្លែងឆ្ងាយៗពីកន្លែងដែលវាកើតឡើង។ បែបនេះបណ្តាលឲ្យមានបញ្ហាសុខភាពដល់ប្រជាជននៅគ្រប់ទីកន្លែង។ ជាទូទៅការបំពុលខ្យល់មានសភាពធ្ងន់ធ្ងរនៅក្នុងទីក្រុង តំបន់ឧស្សាហកម្ម តំបន់ទំនាបឬតំបន់ដែលឡោមព័ទ្ធដោយភ្នំ និងកន្លែងដែលមានខ្យល់បក់មិនបានល្អ។

ការបំពុលខ្យល់អាចផ្ទុកលោហៈធ្ងន់ ដូចជាបារត និងសំណ( មើលទំព័រ337ទៅ340 និង368ទៅ370 ), សារធាតុសរីរាង្គពុលអូសបន្លាយ( POPs )( មើលទំព័រ340 ), និងសារធាតុគីមីពុលដទៃទៀតដូចជាស៊ុលហ្វ័រឌីអុកស៊ីត( sulfur dioxide )។

ប្រសិនបើអ្នកកំពុងតាមដានការបំពុលខ្យល់ក្នុងសហគមន៍ ជាការសំខាន់អ្នកគួរដឹងថាសារធាតុគីមីណាខ្លះដែលមាននៅក្នុងខ្យល់។ ប៉ុន្តែត្រូវចាំថា ការដឹងពីរបៀបការពារខ្លួនអ្នកនិងសហគមន៍អ្នកពីគ្រោះថ្នាក់នៃការបំពុលខ្យល់ គឺសំខាន់ជាងការដឹងថាអ្វីពិតប្រាកដដែលស្ថិតនៅក្នុងខ្យល់។

ការបំពុលខ្យល់បណ្តាលឲ្យមានបញ្ហាសុខភាពធ្ងន់ធ្ងរ ដូចជាជំងឺមហារីក និងជំងឺផ្លូវដង្ហើមជាច្រើន ( មើលទំព័រ327ទៅ331 )។ ការបំពុលខ្យល់បណ្តាលឲ្យមានភ្លៀងអាស៊ីតដែលបំផ្លាញព្រៃឈើ ប្រភពទឹក និងសំណង់អាគារ ក៏ដូចជាសួតរបស់យើងផងដែរ។ ម្យ៉ាងទៀត ការបំពុលខ្យល់គឺជាមូលហេតុចម្បងមួយនៃការឡើងកម្តៅផែនដី( មើលទំព័រ33 )។



# ការតាមដានការបំពុលខ្យល់

ការតាមដានការបំពុលខ្យល់ គឺជាមធ្យោបាយមួយដែលត្រូវបានប្រើប្រាស់ដោយសហគមន៍ ក្នុងអំឡុងយុទ្ធនាការប្រឆាំងនឹងការបំពុលរបស់ក្រុមហ៊ុនឬឧស្សាហកម្ម។ ការតាមដាននេះអនុញ្ញាតឲ្យប្រជាជនជាច្រើនចូលរួមក្នុងយុទ្ធនាការ ក៏ដូចជាការបង្កើតភស្តុតាងដើម្បីដាក់សម្ពាធលើក្រុមហ៊ុនឬឧស្សាហកម្មឲ្យបញ្ឈប់ការបំពុល។

ការតាមដាន ឬការត្រួតពិនិត្យការបំពុលខ្យល់ ចាប់ផ្តើមពីគំនិតសាមញ្ញៗរបស់អ្នក។ ដើម្បីដឹងថាការបំពុលខ្យល់ផ្តល់ផលប៉ះពាល់អ្វីខ្លះលើសហគមន៍របស់អ្នក ចូរសុំឲ្យប្រជាជនកត់ត្រាអំពីអ្វីដែលពួកគេធុំក្លិន មើលឃើញ ស្តាប់ឮ ភ្លក់រសជាតិ ឬមានអារម្មណ៍ដឹង។ កាលណាប្រជាជនធ្វើបែបនេះកាន់តែច្រើន នោះសហគមន៍នឹងមានឱកាសល្អប្រសើរក្នុងការកំណត់អំពីការបំពុលនិងបញ្ឈប់វា។

## មធ្យោបាយកងពលធុងទឹក



សហគមន៍ខ្លះតាមដានខ្យល់ដោយប្រើប្រាស់មធ្យោបាយសាមញ្ញ និងចំណាយតិចមួយ ហៅថា "កងពលធុងទឹក"។ ធុងទឹកប្លាស្ទិកមួយចំណុះ៥ហ្គាឡុង ដែលមានសន្ទះស្នប់មួយ និងថង់ពិសេសមួយត្រូវបានប្រើប្រាស់សម្រាប់ដាក់គំរូខ្យល់។ ពេលបើកសន្ទះស្នប់ក្នុងពេលមានការបញ្ចេញសារធាតុពុល ឬនៅពេលណាដែលខ្យល់ហាក់ដូចជាមានភាពពុលខ្លាំង, នោះបរិមាណខ្យល់បន្តិចបន្តួចនឹងត្រូវបានស្រូបចូលទៅក្នុងថង់។ បន្ទាប់មកគេយកថង់នោះចេញពីធុង រួចបញ្ជូនទៅមន្ទីរពិសោធន៍ដើម្បីស្វែងរកថាតើវាមានសារធាតុគីមីអ្វីខ្លះ។ (មើលផ្នែកធនធាន)។

ការយកគំរូខ្យល់ទៅធ្វើតេស្តនៅមន្ទីរពិសោធន៍ គឺជាផ្នែកដែលចំណាយច្រើនបំផុតនៅក្នុងមធ្យោបាយកងពលធុងទឹក។ ប្រទេសភាគច្រើនមិនមានមន្ទីរពិសោធន៍របស់ខ្លួនដែលអាច(ឬនឹង)ធ្វើតេស្តគំរូខ្យល់យ៉ាងត្រឹមត្រូវទេ ដូច្នេះពួកគេអាចត្រូវបញ្ជូនទៅប្រទេសអឺរ៉ុបឬសហរដ្ឋអាមេរិក។ សហគមន៍ខ្លះរៃអង្គាសប្រាក់ដើម្បីបង្កើតមធ្យោបាយកងពលធុងទឹក ដោយការប្រមូលតាមផ្ទះ ឬការប្រារព្ធពិធីរាំច្រៀង ឬការជួបប្រជុំតាមផ្ទះ។

សហគមន៍ជាច្រើនប្រើប្រាស់មធ្យោបាយកងពលធុងទឹក ជាមួយនឹងសហគមន៍ដទៃទៀតដែលរៀបចំសកម្មភាពដូចជាការធ្វើបទសម្ភាសន៍និងការស្ទង់មតិ។ ពួកគេក៏រាយការណ៍ពីការបញ្ចេញសារធាតុពុលទៅឲ្យប្រព័ន្ធផ្សព្វផ្សាយនិងរដ្ឋាភិបាលផងដែរ និងព្យាយាមបង្ខំរោងចក្រស្លប្រេងកាតនិងឧស្សាហកម្មបំពុលដទៃទៀត ឲ្យប្រើប្រាស់ឧបករណ៍ដែលមានសុវត្ថិភាពប្រសើរ និងកាត់បន្ថយការបំភាយ។

## មធ្យោបាយកងពលធុងទឹកនៃក្រុម "ការងារមូលដ្ឋាន"

ទីក្រុងឌូបាន នៃប្រទេសអាហ្វ្រិកខាងត្បូង គឺជាទីក្រុងដែលឡោមព័ទ្ធទៅដោយរោងចក្រស្លប្រេងកាត និងបំពង់បង្ហូរប្រេង, រោងចក្រគីមី, រោងចក្រវាយនភណ្ឌនិងក្រដាស, និងរណ្ដៅសំរាមពុល។ រៀងរាល់ថ្ងៃ ប្រជាជនក្នុងក្រុងឌូបាន ប្រឈមនឹងការបំពុលខ្យល់កម្រិតខ្ពស់ ការបំពុលទឹក និងបញ្ហាសុខភាពគ្រប់បែបយ៉ាងដែលបណ្ដាលមកពីការប្រឈមជាប្រចាំនឹងសារធាតុគីមីពុល។ ឧប្បត្តិហេតុឧស្សាហកម្ម ការធ្លាយអាងស្តុក និងការធ្លាយបំពង់ប្រេង កើតឡើងជាញឹកញាប់ ដែលបណ្ដាលឲ្យមានភ្លើងឆេះ និងបំផ្លាញដីល្បាយខ្សាច់ និងប្រភពទឹកក្នុងដី។

នៅឆ្នាំ១៩៩៩ ក្រុមមួយហៅថា "ការងារមូលដ្ឋាន" ត្រូវបានបង្កើតឡើងដើម្បីជួយប្រជាជនក្នុងក្រុងឌូបានឲ្យតាមដានការបំពុលខ្យល់។ សហគមន៍បានប្រើមធ្យោបាយកងពលធុងទឹក ដើម្បីធ្វើតេស្ដ៍ខ្យល់នៅពេលណាមានការឆាបឆេះឧស្ម័ន ការផ្ទុះ ឬការសាយភាយសារធាតុពុល។ បន្ទាប់មកពួកគេផ្ញើថង់ដែលពេញទៅដោយខ្យល់ពុលនេះ ទៅកាន់មន្ទីរពិសោធន៍មួយនៅក្នុងសហរដ្ឋអាមេរិកដើម្បីធ្វើតេស្ដ៍។

ការធ្វើតេស្ដ៍នៅមន្ទីរពិសោធន៍បានរកឃើញសារធាតុពុលកម្រិតខ្ពស់ ដូចជាស៊ុលហ្វ៊រឌីអុកស៊ីត (sulfur dioxide) នីត្រូហ្សែនអុកស៊ីត (nitrogen oxide) និងបង់ហ្សែន (benzene)។ លទ្ធផលតេស្ដ៍នៃគំរូខ្យល់ដែលប្រមូលមកតំបន់ក្បែរសាលារៀន បានបង្ហាញថា កុមារបានប្រឈមនឹងការបំពុលក្នុងកម្រិតខ្ពស់មួយដែលដូចគ្នានឹងការឈរពេញមួយថ្ងៃ រៀងរាល់ថ្ងៃ នៅលើមហាវិថីដ៏កុះករ។




សកម្មជនទាំងឡាយបានបង្ហាញលទ្ធផលតេស្ដ៍នេះទៅឲ្យរដ្ឋាភិបាល និងឧស្សាហកម្មពុលទាំងឡាយ ហើយថែមទាំងប្រកាសនៅតាមវិទ្យុ កាសែត និងតាមកន្លែងផ្សេងៗក្នុងសហគមន៍។ ក្រុមហ៊ុនប្រេងរដ្ឋមួយបាននិយាយថា តេស្ដ៍នេះគ្មានភាពសុក្រិតទេ ហើយក៏បានយកគំរូខ្យល់មកពិនិត្យដោយខ្លួនឯង។ ប៉ុន្តែលទ្ធផលតេស្ដ៍របស់ពួកគេបង្ហាញថា មានកម្រិតជាតិពុលរឹតតែខ្ពស់ទៅទៀត!

មធ្យោបាយកងពលធុងទឹក បានជួយបង្កើតចលនាមួយនៅទូទាំងប្រទេស ដើម្បីប្រឆាំងនឹងការបំពុលក្នុងប្រទេសអាហ្វ្រិកខាងត្បូង។ ដោយមានសម្ពាធកាន់តែខ្លាំងឡើងៗពីចលនាយុត្តិធម៌បរិស្ថាន រដ្ឋាភិបាលក៏បានអនុម័តច្បាប់នៃគុណភាពខ្យល់នៅឆ្នាំ២០០៤។ ទីក្រុងឌូបានក៏បានដំឡើងប្រព័ន្ធតាមដានខ្យល់របស់ខ្លួន។ ចាប់ពីពេលនោះមក ការបំពុលខ្យល់ត្រូវបានឃើញថាមានការធ្លាក់ចុះគួរឲ្យកត់សម្គាល់។

មធ្យោបាយកងពលធុងទឹក បានជួយសមាជិកសហគមន៍ឲ្យមានអារម្មណ៍រឹងមាំ ក្លាហាន និងហ៊ានតស៊ូជាមួយឧស្សាហកម្មពុលទាំងឡាយ។ ជាមួយនឹងសេចក្ដីជឿជាក់ខ្ពស់ ពួកគេបានបង្ខំរដ្ឋាភិបាលឲ្យស្ដាប់យោបល់របស់ពួកគេ។

នៅមានបញ្ហាបំពុលយ៉ាងធ្ងន់ធ្ងរមួយទៀតនៅក្នុងប្រទេសអាហ្វ្រិកខាងត្បូង។ ដោយសាររោងចក្រគីមី រោងចក្រស្លប្រេងកាត និងបំពង់ប្រេង មានសភាពចាស់ ពួកគេប្រឈមគ្រោះថ្នាក់ខ្ពស់នៃឧប្បត្តិហេតុនានាដែលអាចកើតឡើង។ ប៉ុន្តែតាមរយៈការរួមបញ្ចូលគ្នារវាងការរៀបចំសហគមន៍យ៉ាងរឹងមាំ ជាមួយនឹងឧបករណ៍សម្រាប់ប្រមូលគំរូនៃភាពបំពុល, ប្រជាជននៃក្រុងឌូបាន បានធ្វើឲ្យខ្លួនគេមានសុវត្ថិភាពប្រសើរ។ ហើយពួកគេបានបង្ហាញប្រជាជនដទៃទៀតនៅក្នុងប្រទេសនិងទូទាំងពិភពលោក ថាប្រជាជនអាចធ្វើឲ្យឧស្សាហកម្មនិងរដ្ឋាភិបាលទទួលខុសត្រូវលើការបំពុលរបស់ខ្លួន។

# នៅពេលមានការបញ្ចេញសារធាតុពុល

រោងចក្រគីមី រោងចក្រស្លប្រេងកាត និងរោងចក្រដទៃទៀត អាចមានឧប្បត្តិហេតុផ្សេងៗដែលធ្វើឲ្យបញ្ចេញសារធាតុគីមីពុលយ៉ាងច្រើនក្នុងពេលភ្លាមៗ។ ម្យ៉ាងទៀត នៅក្នុង"ការថៃទាំជាប្រចាំ" រោងចក្រស្លប្រេងកាតក៏បញ្ចេញឧស្ម័នពុលផងដែរ។ ការបញ្ចេញសារធាតុពុលអាចមើលទៅដូចជាដុំពពកផ្សែងឬភ្លើងយ៉ាងធំ ឬមានក្លិនឆ្អួលភ្លាមៗ។ បែបនេះគួរឲ្យរន្ធត់ណាស់។ វាក៏អាចធ្វើឲ្យស្លាប់ដែរ។

ក្នុងរយៈពេលខ្លី ប្រជាជនអាចអនុវត្តជំហានមួយចំនួនក្នុងពេលនិងក្រោយពេលមានការបញ្ចេញសារធាតុពុលនិងការកំពប់គីមីមួយលើកៗ ដើម្បីកាត់បន្ថយគ្រោះថ្នាក់(មើលសេចក្តីបន្ថែម ក)។ ក្នុងរយៈពេលវែង សហគមន៍ត្រូវរៀបចំសកម្មភាពផ្សេងៗដើម្បីដាក់សម្ពាធលើឧស្សាហកម្មនិងរដ្ឋាភិបាលឲ្យអនុវត្តបទបញ្ជាសុវត្ថិភាព។

**ក្នុងពេលបញ្ចេញសារធាតុពុល :**

- អាស្រ័យលើស្ថានភាព និងភាពរហ័សរហួនរបស់អ្នក ជួនកាលអ្នកគ្រាន់តែនៅក្នុងផ្ទះគឺមានសុវត្ថិភាព។ ក្នុងស្ថានភាពខ្លះទៀត អ្នកត្រូវរត់ចេញពីតំបន់នោះឲ្យឆាប់បំផុតទើបមានសុវត្ថិភាព។ ការបណ្តុះបណ្តាល និងផែនការភាពអាសន្នក្នុងសហគមន៍ នឹងជួយអ្នកឲ្យដឹងថាពេលណាគួរនៅក្នុងផ្ទះ និងពេលណាគួរចេញពីផ្ទះ។
- កត់ត្រាហេតុការណ៍មួយចំនួន។ កត់ចំណាំពេលវេលានៃការបញ្ចេញ និងរយៈពេលនៃការបញ្ចេញ។ ដូចគ្នាដែរ គួរកត់ចំណាំលើក្លិនគំហើញ សំឡេង និងប្រតិកម្មរាងកាយផ្សេងៗ (អារម្មណ៍ក្នុងខ្លួន)ដែលចម្លែកៗ ព្រមទាំងប្រតិកម្មនៃប្រជាជនដទៃនិងសត្វដែលនៅជុំវិញអ្នក។ ព័ត៌មានទាំងនេះអាចមានសារសំខាន់នៅពេលក្រោយ ក្នុងពេលធ្វើសកម្មភាពសហគមន៍។
- ថតរូបភាពនិងរូបវីដេអូ ប្រសិនបើអាចថតដោយសុវត្ថិភាព។ អ្នកអាចប្រើប្រាស់វានៅពេលក្រោយនៅក្នុងតុលាការឬយុទ្ធនាការផ្សេងៗ។

**ក្រោយពេលបញ្ចេញសារធាតុពុល :**

- ប្រសិនបើប្រជាជនបានប្រឈមនឹងសារធាតុគីមី ជួយនាំពួកគេឲ្យទៅគ្លីនិកឬមន្ទីរពេទ្យភ្លាមៗ។
- ទាក់ទងអាជ្ញាធរនិងប្រព័ន្ធផ្សព្វផ្សាយដើម្បីរាយការណ៍ពីអ្វីដែលបានកើតឡើង។
- រៀបចំការប្រជុំមួយដើម្បីប្រាប់មនុស្សទាំងអស់គ្នានៅក្នុងសហគមន៍ឲ្យដឹងថាមានអ្វីកើតឡើង រួចរៀបចំការឆ្លើយតបរបស់សហគមន៍។
- លើកទឹកចិត្តសមាជិកសហគមន៍ឲ្យចែករំលែកបទពិសោធន៍និងអារម្មណ៍របស់ខ្លួន។ បែបនេះនឹងជួយប្រជាជនឲ្យងើបចេញពីព្រឹត្តិការណ៍នោះ ព្រមទាំងបង្កើតសាមគ្គីភាពក្នុងសហគមន៍។




**ការគូសចំណាំនៅលើប្រតិទិន គឺជាវិធីដ៏ល្អមួយក្នុងការកត់ត្រាអំពីការបញ្ចេញសារធាតុពុល។**

# ផលិតកម្មស្អាត

បច្ចេកវិទ្យា និងមធ្យោបាយផ្សេងៗ កើតឡើងដើម្បីផលិតនិងលក់ផលិតផលដោយមិនបង្កការបំពុលឬកាកសំណល់ពុលទេ។ **ផលិតកម្មស្អាត** ការពារសុខភាពរបស់ប្រជាជន និងសុខភាពរបស់បរិស្ថាន។

**តើរោងចក្រក្រដាសប្រើប្រាស់ផលិតកម្មស្អាតយ៉ាងដូចម្តេច**




រោងចក្រក្រដាសប្រើប្រាស់ដើមឈើ ទឹក អគ្គិសនី និងសារធាតុគីមី ដូចជាក្លរីន ជាដើម។ រោងចក្រក្រដាសដែលមានផលិតកម្មស្អាត កាត់បន្ថយការបំពុលតាមរយៈការប្រើប្រាស់ ៖

- ក្រដាសដែលភាគច្រើនជាក្រដាសសម្រាប់កែច្នៃឡើងវិញ និងដើមឈើមកពីព្រៃឈើដែលបានគ្រប់គ្រងយ៉ាងមានចិរភាព។
- ប្រភពថាមពលដែលអាចធ្វើថ្មីវិញបាន (ដូចជាពន្លឺថ្ងៃ ឬថាមពលខ្យល់) ជាជាងអគ្គិសនីពីឥន្ធនៈហ្វូស៊ីល ដូចជាប្រេង ឬធ្យូង។
- មិនប្រើប្រាស់សារធាតុក្លរីន ឬសារធាតុគីមីពុលដទៃទៀត។
- ទឹកតិចបំផុតតាមដែលអាច។ ទឹកត្រូវបានប្រើប្រាស់ឡើងវិញជាច្រើនដង បន្ទាប់មកត្រូវបានសម្លាប់មេរោគមុននឹងចោលទៅក្នុងបរិស្ថានវិញ។

ឧស្សាហកម្មភាគច្រើន អាចប្រើប្រាស់ដំណើរការផលិតកម្មស្អាតបាន។ កម្តៅចេញពីរោងចក្រអាចត្រូវបានប្រើសម្រាប់ផលិតអគ្គិសនី ហើយជាញឹកញាប់ កាកសំណល់ផលិតផលអាចត្រូវបានប្រើជាសម្ភារៈនៅក្នុងផលិតផលផ្សេងទៀត។ ផលិតកម្មស្អាត អាចកាត់បន្ថយកាកសំណល់ស្ទើរតែគ្មានសល់ឡើយ។ ហើយដោយសារផលិតកម្មស្អាត ប្រើប្រាស់សម្ភារៈនិងថាមពលឡើងវិញ ដូច្នេះវាក៏សន្សំសំចៃប្រាក់ផងដែរ។

ប៉ុន្តែដោយហេតុតែក្រុមហ៊ុនមិនចំណាយលើការសម្អាត ឬលើការបង្ការការបំពុលនិងគ្រោះថ្នាក់ដែលគេបង្កឡើងទេ ដូច្នេះជាទូទៅពួកគេត្រូវបានបង្ខំឲ្យផ្លាស់ប្តូរទៅប្រើប្រាស់មធ្យោបាយផលិតកម្មស្អាតវិញ ដោយសារមានសម្ពាធពីប្រជាជន ឬបទបញ្ជារបស់រដ្ឋាភិបាល។

# ការលើកកម្ពស់ក្រុមហ៊ុនពាណិជ្ជកម្មស្អាត

នៅពេលម្ចាស់ក្រុមហ៊ុននិងកម្មករ យល់អំពីគ្រោះថ្នាក់នៃសារធាតុគីមីនិងកាកសំណល់ឧស្សាហកម្ម មកលើមនុស្សគ្រប់គ្នានៅក្នុងសហគមន៍ ជាទូទៅពួកគេមានឆន្ទៈនឹងធ្វើការផ្លាស់ប្តូរនូវសម្ភារៈនិងមធ្យោបាយផលិតកម្ម ដើម្បីកាត់បន្ថយគ្រោះថ្នាក់។ ទោះជាយ៉ាងនេះក្តី ជួនកាលយើងចាំបាច់ត្រូវដាក់សម្ពាធលើពួកគេ ដោយទាំងវិធីវិជ្ជមាននិងអវិជ្ជមាន ដើម្បីសម្រេចឲ្យបានការផ្លាស់ប្តូរនានាដែលនឹងផ្តល់ផលប្រយោជន៍ដល់សុខភាពសហគមន៍។ មានវិធីផ្សេងៗដើម្បីដាក់សម្ពាធលើក្រុមហ៊ុនឲ្យជ្រើសរើសយកមធ្យោបាយផលិតកម្មស្អាតវិញ។

**រដ្ឋាភិបាលអាច :** ហាមឃាត់ឬដាក់កម្រិតលើការប្រើប្រាស់សារធាតុគីមីពុល និងដំណើរការផលិតកម្មដែលគ្រោះថ្នាក់, ផ្តល់មូលនិធិដល់ក្រុមហ៊ុនដើម្បីឲ្យពួកគេផ្លាស់ប្តូរទៅប្រើប្រាស់មធ្យោបាយផលិតកម្មស្អាត, យកពន្ធទាបចំពោះក្រុមហ៊ុនដែលប្រើប្រាស់ផលិតកម្មស្អាត, និងយកពន្ធខ្ពស់ចំពោះក្រុមហ៊ុនដែលប្រើប្រាស់មធ្យោបាយគ្រោះថ្នាក់។

**ប្រជាជនអាច :** អប់រំខ្លួនឯង ម្ចាស់ក្រុមហ៊ុន និងកម្មករ អំពីគ្រោះថ្នាក់នៃសារធាតុពុល និងពីផលប្រយោជន៍នៃមធ្យោបាយផលិតកម្មស្អាត, ធ្វើពហិកាមិនទិញផលិតផលដែលផលិតឬលក់ដោយក្រុមហ៊ុនដែលបំពុល, ប្រាប់អ្នកដទៃអំពីផលិតផលដែលមិនពុល ដែលអាចប្រើជំនួសផលិតផលពុលបាន, ប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយដើម្បីបកអាក្រាតសារជីវកម្មដែលបំពុល និងលើកសរសើរពីជោគជ័យនៃក្រុមហ៊ុនដែលមិនបំពុល និងដែលមានចិរភាព។




**កម្មករអាច :** រៀននិងអនុវត្តតាមច្បាប់ស្តីពីការរៀបចំសារធាតុពុលប្រកបដោយសុវត្ថិភាព, និងសរសេរក្នុងកុងត្រាសហជីពរបស់ខ្លួនអំពីការការពារកម្មករនិងសហគមន៍ ទប់ទល់នឹងសារធាតុពុល។

# ពាណិជ្ជកម្មស្អាតតូចតាច

ជួនកាល ម្ចាស់ពាណិជ្ជកម្មតូចតាចមិនយល់ច្បាស់ពីគ្រោះថ្នាក់ដែលអាចបង្កឡើងដោយសារធាតុពុលទេ។ នៅពេលពួកគេនិងកម្មកររបស់គេ ប្រើប្រាស់ រក្សាទុក និងបោះចោលសារធាតុគីមីពុលតាមរបៀបដែលគ្មានសុវត្ថិភាព ជាទូទៅពួកគេគ្រាន់តែព្យាយាមសន្សំសំចៃប្រាក់ ពេលវេលា និងពលកម្មប៉ុណ្ណោះ។ ចុងក្រោយ អ្នកជំនួញជាច្រើនរស់នៅក្នុងសហគមន៍តែមួយដែលពួកគេកំពុងបំពុល ហើយអ្នកទាំងនេះគឺជាមិត្តភក្តិ និងអ្នកជិតខាងនៃប្រជាជនដែលរងផលប៉ះពាល់។ ឬមួយពួកគេអាចដឹងអំពីមធ្យោបាយផលិតកម្មស្អាត ប៉ុន្តែមានអារម្មណ៍ថាគ្មានលទ្ធភាពចំណាយលើការផ្លាស់ប្តូរទេ។ ប៉ុន្តែក្នុងពេលខាងមុខ ការចំណាយលើការថែទាំសុខភាពនៃកម្មករដែលរបួស និងលើការសម្អាតបរិស្ថានក្នុងសហគមន៍ នឹងមានតម្លៃច្រើនជាងប្រាក់និងពេលវេលាដែលពួកគេសន្សំសំចៃទៅទៀត។

នៅពេលពាណិជ្ជកម្មតូចតាច ផ្លាស់ប្តូរទៅអនុវត្តផលិតកម្មស្អាត ពួកគេនឹងជួយសហគមន៍ទាំងមូល ហើយអនាគតនៃពាណិជ្ជកម្មរបស់ពួកគេ កាន់តែមានចិរភាព។

# ការជ្រលក់ថ្នាំពណ៌

ថ្នាំជ្រលក់ពណ៌ជាច្រើនត្រូវបានផលិតពីលោហៈធ្ងន់ និងសារធាតុគីមីពុលដទៃទៀត។ ជាញឹកញាប់ កាកសំណល់ចេញពីការផលិតថ្នាំជ្រលក់ពណ៌ ត្រូវបានចាក់ចូលក្នុងផ្លូវទឹក ដែលធ្វើឲ្យមានសារធាតុពុល ដ៏គ្រោះថ្នាក់ និងពិបាកសម្អាតណាស់។

### វិធីកាត់បន្ថយការបំពុល

ពាណិជ្ជកម្មតូចតាចក្នុងផ្នែកឧស្សាហកម្មថ្នាំជ្រលក់ពណ៌ អាចកាត់បន្ថយកាកសំណល់គ្រោះថ្នាក់ ដោយអនុវត្តតាមការណែនាំទាំងនេះ ៖

- ចៀសវាងថ្នាំជ្រលក់ពណ៌ដែលពុលខ្លាំងបំផុត ដូចជាថ្នាំជ្រលក់ពណ៌Azo, និងរកមើលថ្នាំជំនួស ផ្សេងដែលមានសុវត្ថិភាពជាង។ ថ្នាំជ្រលក់ពណ៌Azo ដែលត្រូវបានដឹងថាបណ្តាលឲ្យមានពិការភាព ពីកំណើត គឺត្រូវបានប្រើប្រាស់ញឹកញាប់នៅក្នុងការបោះពុម្ព វាយនភណ្ឌ រោងចក្រផលិតក្រដាស រោងចក្រផលិតថ្នាំពេទ្យ និងឧស្សាហកម្មអាហារ។
- គ្រប់គ្រងបរិមាណនៃសារធាតុពុលដែលបានប្រើប្រាស់។
- ប្រើប្រាស់អនុផលពីថ្នាំជ្រលក់ពណ៌ ធ្វើជាសម្ភារៈសម្រាប់បង្កើតផលិតផលដទៃទៀត។
- ប្រើប្រាស់ទឹកសម្អាតឡើងវិញ ដើម្បីបង្កើតថ្នាំជ្រលក់ពណ៌បន្ទាប់ទៀត។
- ប្រើប្រាស់ទឹកសម្អាតដែលបាញ់ចេញពីទុយោដោយសម្ពាធខ្លាំង ដើម្បីកាត់បន្ថយបរិមាណ ទឹកសំណល់។
- បិទស្លាកសញ្ញានិងរក្សាទុកសម្ភារៈពុល នៅក្នុងកន្លែងសុវត្ថិភាពដែលស្ថិតនៅឆ្ងាយពីផ្លូវទឹក។

# រោងចក្រកែច្នៃស្បែក

រោងចក្រកែច្នៃស្បែក ប្រើប្រាស់ទឹក អំបិល និងសារធាតុគីមីពុល(ដូចជាទម្រង់ផ្សេងៗនៃក្រូមីញ៉ូម) ក្នុង បរិមាណយ៉ាងច្រើន ។ នៅចុងបញ្ចប់នៃដំណើរការកែច្នៃស្បែក សារធាតុគីមីទាំងនេះភាគច្រើនត្រូវបានចាក់ ចូលក្នុងទន្លេនិងផ្លូវទឹកដទៃទៀត។ ជាលទ្ធផល សហគមន៍ទាំងឡាយដែលនៅជុំវិញរោងចក្រកែច្នៃស្បែក ច្រើនតែមានទឹកផឹកដែលត្រូវបានបំពុលយ៉ាងខ្លាំង។

ក្នុងរយៈពេលខ្លី សារធាតុពុលទាំងនេះអាចបណ្តាលឲ្យមានជំងឺរលាកទងសួត ជំងឺហឺត និងបញ្ហាដង្ហើម ផ្សេងទៀត។ ក្នុងរយៈពេលវែង ការប្រឈមជាបន្តបន្ទាប់ អាចបណ្តាលឲ្យមានពិការភាពពីកំណើត និងជំងឺ មហារីក។

### វិធីកាត់បន្ថយការបំពុល

រោងចក្រកែច្នៃស្បែកខ្លះ ប្រើប្រាស់មធ្យោបាយផលិតកម្មដែលមិនបំពុល ឬមិនសូវបំពុល។ មធ្យោបាយបុរាណ នៃការកែច្នៃស្បែក គឺគេប្រើប្រាស់ផ្នែកផ្សេងៗរបស់សត្វសម្រាប់ការរម្ងាប់ស្បែកដែលមានសុវត្ថិភាពជាងនិង ស្អាតជាង។ ចំពោះរោងចក្រកែច្នៃស្បែកដែលប្រើប្រាស់ក្រូមីញ៉ូម មានវិធីកែច្នៃក្រូមីញ៉ូមឡើងវិញ ដូច្នេះវាត្រូវ បានប្រើប្រាស់បន្តិចបន្តួច និងមិនសូវមានកាកសំណល់ច្រើន។ បែបនេះកាត់បន្ថយទាំងការចំណាយ និងការ បំពុល។ ទឹកដែលប្រើក្នុងការរម្ងាប់ស្បែក អាចកែច្នៃប្រើឡើងវិញបាន ហើយទឹកកាកសំណល់អាចត្រូវបាន រម្ងាប់មេរោគដើម្បីអាចចាក់វាចោលដោយសុវត្ថិភាព។

## ផលិតកម្មស្អាតនៅក្នុងរោងចក្រកែច្នៃស្បែក



ទីក្រុងលីយ៉ន(Leon)នៃប្រទេសម៉ិកស៊ិកូ មានភាពល្បីល្បាញដោយសារស្បែកជើងស្បែកគុណភាពខ្ពស់របស់ពួកគេ។ រោងចក្រកែច្នៃស្បែកនៅក្នុងទីក្រុងលីយ៉ន គឺជាពាណិជ្ជកម្មតូចៗ ដែលមានសារសំខាន់សម្រាប់សេដ្ឋកិច្ចក្នុងសហគមន៍។ ជាអកុសលប្រតិបត្តិការកែច្នៃស្បែក ធ្លាប់បានចាក់កាកសំណល់គីមីចូលទៅក្នុងផ្លូវទឹកដោយផ្ទាល់ធ្វើឲ្យប្រជាជនជាច្រើនមានជំងឺធ្ងន់ធ្ងរ។

ច្រើនឆ្នាំកន្លងទៅ ក្រុងលីយ៉នបានអនុម័តច្បាប់រឹតបន្តឹងការបំពុល ប៉ុន្តែរោងចក្រកែច្នៃស្បែកទាំងនោះសឹងតែមិនដែលគោរពម្តងណាឡើយ។ ម្ចាស់រោងចក្រជាច្រើនគិតថា ការកាត់បន្ថយការបំពុលគឺត្រូវចំណាយច្រើនណាស់ ហើយវានឹងប៉ះពាល់ដល់ពាណិជ្ជកម្មរបស់ពួកគេ។

ទោះជាយ៉ាងនេះក្តី នៅពេលសត្វស្លាបរាប់ពាន់ក្បាលបានស្លាប់ដោយសារការបំពុលនៅទីដីល្បាយខ្សាច់មួយក្បែរក្រុងលីយ៉ន, អង្គការពាណិជ្ជកម្មក្នុងតំបន់ដែលតំណាងឲ្យរោងចក្រកែច្នៃស្បែក បានចាប់ផ្តើមស្វែងរកវិធីកាត់បន្ថយការបំពុលដោយមិនធ្វើឲ្យប៉ះពាល់ដល់ពាណិជ្ជកម្មរបស់ខ្លួន។ នៅពេលនោះពួកគេក៏បានស្វែងយល់អំពីផលិតកម្មស្អាត។

ជាច្រើនឆ្នាំបន្ទាប់មកទៀត អង្គការពាណិជ្ជកម្មនេះបានជួយរោងចក្រកែច្នៃស្បែកឲ្យកាត់បន្ថយការបំពុល ហើយរោងចក្រកែច្នៃស្បែកជាច្រើន បានផ្លាស់ប្តូរការអនុវត្តរបស់ខ្លួន។ ពួកគេធ្វើដូចនេះគឺមិនមែនគ្រាន់តែចង់ការពារប្រភពទឹកផឹក ឬសត្វស្លាបប៉ុណ្ណោះទេ។ ពួកគេធ្វើនេះក៏ដោយសារមើលឃើញថាផលិតកម្មស្អាតអាចសន្សំសំចៃប្រាក់ និងផលិតស្បែកដែលមានគុណភាពកាន់តែល្អ។

រោងចក្រកែច្នៃស្បែកទាំងឡាយនៅក្នុងបណ្តាប្រទេសអាហ្វ្រិកនិងអាស៊ី បានធ្វើការងារជាមួយអង្គការអភិវឌ្ឍន៍ឧស្សាហកម្មនៃអង្គការសហប្រជាជាតិ(UNIDO) ដើម្បីស្វែងរកវិធីផ្សេងៗក្នុងការកែច្នៃនិងប្រើប្រាស់ឡើងវិញនូវសារធាតុគីមីដែលបានប្រើប្រាស់នៅក្នុងការសម្លាប់ស្បែក។ គម្រោងផលិតកម្មស្អាតនៃអង្គការ UNIDO បានបង្ហាញថា ជាងពាក់កណ្តាលនៃការបំពុលដែលចេញពីរោងចក្រកែច្នៃស្បែក អាចត្រូវបានកាត់បន្ថយតាមរយៈការប្រើប្រាស់ធនធានធម្មជាតិយ៉ាងមានប្រសិទ្ធភាពនិងដោយប្រុងប្រយ័ត្ន - ប្រើប្រាស់ក្នុងបរិមាណតិចជាងមុន និងប្រើដោយប្រុងប្រយ័ត្នបំផុត។

រោងចក្រកែច្នៃស្បែកក្នុងទីក្រុងលីយ៉ន បានរៀនតាមគម្រោងរបស់អង្គការUNIDO ហើយបានចាប់ផ្តើមអនុវត្តមធ្យោបាយផលិតកម្មស្អាត។ ដំបូងពួកគេប្រើប្រាស់ដំណើរការថ្មីមួយដែលធ្វើឲ្យក្រូមីញ៉ូមក្នុងទឹករម្ងាប់ស្បែក ប៉ះពាល់យ៉ាងច្រើនជាមួយនឹងស្បែកសត្វ ហើយក្រូមីញ៉ូមបន្តិចបន្តួចក្លាយជាកាកសំណល់។ បន្ទាប់មក អង់ហ្ស៊ីម(ផលិតផលធម្មជាតិដែលធ្វើឲ្យមានការប្រែប្រួលគីមី) បានជំនួសសារធាតុគីមីពុលដែលប្រើសម្រាប់បន្ទន់ស្បែកសត្វ។ រោងចក្រកែច្នៃស្បែកខ្លះដែលផលិតស្បែកគុណភាពទាប បានចាប់ផ្តើមប្រើប្រាស់របៀបសម្លាប់ស្បែកដែលប្រើបន្លែ ជាជាងការប្រើក្រូមីញ៉ូម ដូច្នេះពួកគេបានបំបាត់ចោលនូវផ្នែកមួយដែលពុលជាខ្លាំងនិងមានតម្លៃខ្ពស់នៅក្នុងដំណើរការកែច្នៃស្បែកនេះ។

រោងចក្រកែច្នៃស្បែកដែលមិនអាចរកមធ្យោបាយជំនួសក្រូមីញ៉ូមទេ បានចាប់ផ្តើមប្រើប្រាស់វាឡើងវិញ ជាជាងចាក់វាចោលបន្ទាប់ពីប្រើតែមួយលើក។ ដូចគ្នាដែរចំពោះទឹកកខ្វក់ រោងចក្រកែច្នៃស្បែកខ្លះបានបង្កើតប្រព័ន្ធរម្ងាប់មេរោគលើទឹកសំណល់ ដើម្បីសម្អាតវានិងកែច្នៃវាសម្រាប់ប្រើប្រាស់ឡើងវិញ ដែលចំណុចនេះពួកគេបានការពារនិងបម្រុងប្រភពទឹក។

បច្ចុប្បន្នកម្មកររោងចក្រកែច្នៃស្បែកនៅក្រុងលីយ៉ន ដឹងអំពីផលិតកម្មស្អាត។ នៅពេលអ្នកសួរថាហេតុអ្វីពួកគេប្រើប្រាស់មធ្យោបាយថ្មីទាំងនេះ ពួកគេអាចនឹងប្រាប់អ្នកថាដើម្បីការពារប្រភពទឹក។ ប៉ុន្តែពួកគេក៏នឹងប្រាប់អ្នកផងដែរថា ឥឡូវនេះពួកគេផលិតស្បែកដែលមានគុណភាពកាន់តែខ្ពស់ ដោយចំណាយតិចជាងមុនទៅទៀត។

## បទពិសោធន៍នៃផលិតកម្មស្អាត

ទេសភាពស្រស់ត្រកាលនៅលើកំពូលភ្នំក្នុងរដ្ឋសាន់ហ្វ្រាន់ស៊ីស្កូ នៃសហរដ្ឋអាមេរិក ទាក់ទាញភ្ញៀវទេសចរមកពីគ្រប់ទីកន្លែងនៃពិភពលោក។ ភោជនីយដ្ឋានតូចៗជាច្រើន បម្រើអាហារយ៉ាងច្រើនប្រភេទដល់ពួកទេសចរ។ ប៉ុន្តែ ជាមួយនឹងភោជនីយដ្ឋានជាច្រើន ប្រេងសំណល់ពីការចម្អិន បានក្លាយជាបញ្ហាមួយដែលធ្វើឲ្យស្ទះលូបង្ហូរ និងធ្វើឲ្យទីក្រុងចំណាយប្រាក់ដោយបញ្ហានេះ។ ក្រុងទាមទារភោជនីយដ្ឋានទាំងអស់ឲ្យប្រើប្រាស់ "បំពង់ចាប់ប្រេង" ដើម្បីបង្ការវាកុំឲ្យចូលក្នុងលូបង្ហូរ ប៉ុន្តែការចាក់ចោលនិងសម្អាតបំពង់ចាប់ប្រេង ត្រូវចំណាយប្រាក់ច្រើន។ ពាណិជ្ជកម្មតូចៗជាច្រើនដែលគ្រប់គ្រងដោយជនអន្តោប្រវេសន៍ថ្មីៗ មិនមានចំណាយលើការសម្អាតនេះទេ។

គណៈកម្មការផលប្រយោជន៍សាធារណៈ នៃរដ្ឋសាន់ហ្វ្រាន់ស៊ីស្កូ ដែលទទួលខុសត្រូវលើប្រព័ន្ធលូក្នុងទីក្រុង បានសម្រេចចិត្តថា ជំនួសឲ្យការដាក់ពិន័យធ្ងន់ធ្ងរលើភោជនីយដ្ឋានទាំងឡាយដែលមិនបានចោលប្រេងសំណល់របស់ខ្លួនត្រឹមត្រូវ ពួកគេបានផ្តល់ជាដំណោះស្រាយមួយវិញ។ ពួកគេនឹងប្រមូលប្រេងសំណល់ រួចប្រើវាសម្រាប់ដំណើរការរថយន្តក្រុង!

នៅពេលម៉ាស៊ីនម៉ាស៊ូតត្រូវបានបង្កើតឡើង វាដុតឥន្ធនៈស្រាលៗដូចជាប្រេងបន្លែជាដើម។ ប៉ុន្តែដោយសារប្រេងឆៅមានតម្លៃថោក និងសម្បូរ ហើយក្រុមហ៊ុនដែលផលិតវា មានឥទ្ធិពលខ្លាំង ដូច្នេះម៉ាស៊ីនម៉ាស៊ូតក៏បានចាប់ផ្តើមប្រើប្រាស់ប្រេងឆៅ។ ឥឡូវ ដោយមានបញ្ហាបំពុលធ្ងន់ធ្ងរ និងការឡើងកម្តៅផែនដីដែលបង្កឡើងដោយប្រេងឆៅ ប្រជាជនកំពុងត្រឡប់ទៅរកប្រេងបន្លែធ្វើជាឥន្ធនៈស្អាត ហើយវាមិនថ្លៃដូចប្រេងឆៅផង។

បន្ទាប់ពីការកែច្នៃបន្តិចបន្តួច ម៉ាស៊ីនម៉ាស៊ូតអាចប្រើប្រេងបន្លែបាន ឬគេអាចប្រែក្លាយប្រេងបន្លែឲ្យទៅជា "ប្រេងជីវៈ" ដែលអាចប្រើជាមួយម៉ាស៊ីនម៉ាស៊ូតដោយមិនចាំបាច់កែច្នៃ។ ការដុតប្រេងជីវៈ កាត់បន្ថយការបំពុលខ្យល់យ៉ាងច្រើនដែលបង្កជំងឺហឺតនិងមហារីក ហើយវាមិនបណ្តាលឲ្យឡើងកម្តៅផែនដីទេ។ បើប្រៀបធៀបជាមួយឥន្ធនៈដទៃទៀត ដូចជាឧស្ម័នធម្មជាតិជាដើម ប្រេងជីវក៏មានតម្លៃថោកជាងដែរ។

ការផលិតប្រេងជីវៈដោយការកែច្នៃប្រេងសំណល់ គឺខុសគ្នានឹងការដាំដំណាំគ្រាន់តែដើម្បីផលិតប្រេង។ ការកែច្នៃ បង្ការប្រេងសំណល់មិនឲ្យចូលក្នុងលូ ហើយយកវាទៅប្រើប្រាស់ថែមទៀត។

ដើម្បីធ្វើឲ្យផលិតកម្មស្អាតមានដំណើរការ គណៈកម្មការផលប្រយោជន៍សាធារណៈនៃរដ្ឋសាន់ហ្វ្រាន់ស៊ីស្កូ បានជួលអ្នកនិយាយភាសាដើមកំណើតជាច្រើនអ្នក ឲ្យទៅជួបជជែកជាមួយម្ចាស់ភោជនីយដ្ឋានទាំងឡាយ និងប្រមូលប្រេងសំណល់។ ម្ចាស់ភោជនីយដ្ឋានលែងចំណាយប្រាក់លើការចោលប្រេងរបស់ខ្លួនទៀតហើយ ហើយក្រុងបានទទួលផលប្រយោជន៍វិញដែរ គឺលែងសូវមានប្រេងស្ទះប្រព័ន្ធលូ និងមានឥន្ធនៈថោកសម្រាប់រថយន្តក្រុង។




ឥឡូវនេះ ផ្លូវទាំងឡាយក្នុងរដ្ឋសាន់ហ្វ្រាន់ស៊ីស្កូ ធុំក្លិនឈ្ងុយម្ហូបអាហារគ្រប់មុខ ដែលទាក់ទាញពួកទេសចរកាន់តែច្រើនមកភោជនីយដ្ឋានតូចៗទាំងនេះ។

# ការចោលកាកសំណល់ពុលដោយគ្មានសុវត្ថិភាព

ក្រុមហ៊ុនដែលមិនប្រើប្រាស់មធ្យោបាយផលិតកម្មស្អាត ច្រើនតែបង្កើតកាកសំណល់ពុលយ៉ាងច្រើន។ ឧស្សាហកម្មខ្លះ ដូចជាឧស្សាហកម្មគីមី និងឧស្សាហកម្មរ៉ែនិងប្រេង, កាកសំណល់ពុលអាចជាផលិតផលដ៏ធំបំផុតរបស់ពួកគេ!

ដោយសារកាកសំណល់ពុលពិបាកនឹងបោះចោលឲ្យមានសុវត្ថិភាពនិងត្រូវការចំណាយយ៉ាងច្រើន ដូច្នេះទើបការចាក់ចោលកាកសំណល់គ្រោះថ្នាក់ កើតមានជាញឹកញាប់។ ហើយម្យ៉ាងទៀត ការចាក់ចោលកាកសំណល់ក៏បន្ថែមប្រភពនៃជំងឺមួយទៀតដល់ប្រជាជនដែលរស់នៅក្នុងសហគមន៍ក្រីក្រ។

ក្រុមហ៊ុនកាន់តែច្រើនត្រូវបានណែនាំឲ្យរក្សាផលិតផលពុលរបស់ខ្លួនកុំឲ្យទៅជាកាកសំណល់ តាមរយៈការកែច្នៃកាកសំណល់ផ្នែកខ្លះឡើងវិញឬផ្នែកទាំងមូល។ ប៉ុន្តែសូម្បីតែសកម្មភាពមិនបំផ្លាញបរិស្ថាន ដូចជាការកែច្នៃធនធាន ក៏ត្រូវតែធ្វើដោយប្រុងប្រយ័ត្នដែរ ដើម្បីបង្ការសារធាតុពុលកុំឲ្យបង្កគ្រោះថ្នាក់ដល់កម្មករនិងបរិស្ថាន។

ការធ្វើឲ្យប្រាកដថាឧស្សាហកម្មបោះចោលកាកសំណល់របស់ខ្លួនដោយមានការទទួលខុសត្រូវ គឺគ្រាន់តែជាផ្នែកមួយនៃដំណោះស្រាយប៉ុណ្ណោះ។ ដើម្បីបញ្ឈប់បញ្ហានៃកាកសំណល់ពុលយ៉ាងពិតប្រាកដ យើងត្រូវតផ្លាស់ប្តូររបៀបធ្វើការរបស់ឧស្សាហកម្ម។ វិធីសុវត្ថិភាពតែមួយគត់ក្នុងការបោះចោលកាកសំណល់ពុល គឺត្រូវបញ្ឈប់ការបង្កើតកាកសំណល់នេះតាំងពីទីដំបូងមក។

## គម្រោងស្តុកទុកកាកសំណល់នៃបណ្តាប្រទេសអាហ្វ្រិក

ច្រើនទសវត្សរ៍មកហើយ សាជីវកម្មនិងភ្នាក់ងារអភិវឌ្ឍន៍នានា បានលើកកម្ពស់ថ្នាំសម្លាប់សត្វល្អិតដល់កសិករ ដែលចាត់ទុកវាជាផ្នែកមួយនៃដំណោះស្រាយភាពអត់ឃ្លាន។ ប៉ុន្តែ ឥឡូវនេះអ្នកវិទ្យាសាស្ត្រនិងកសិករជាច្រើនបានដឹងថា ថ្នាំសម្លាប់សត្វល្អិតបង្កបញ្ហាច្រើនជាងអ្វីដែលវាដោះស្រាយទៅទៀត។ តើនរណានឹងបោះចោលសារធាតុគីមីពុលដល់ជីវិតទាំងនេះ? តើវាត្រូវបោះចោលឲ្យមានសុវត្ថិភាពយ៉ាងដូចម្តេច?

នៅតាមប្រទេសនានាក្នុងទ្វីបអាហ្វ្រិក មានថ្នាំសម្លាប់សត្វល្អិតដែលមិនប្រើប្រាស់និងមិនចង់បាន ជាង ៥០.០០០តោន និងកាកសំណល់ពុលដទៃទៀត ត្រូវបានរក្សាទុកក្នុងធុងធ្លាយ។ ដើម្បីសម្អាតសារធាតុពុលទាំងនេះ និងដើម្បីបង្ការការចាក់ចោលកាកសំណល់ពុលបន្ថែមទៀត ភ្នាក់ងាររដ្ឋាភិបាលនិងអង្គការអន្តរជាតិមួយក្រុម បានបង្កើតកម្មវិធីស្តុកទុកកាកសំណល់នៃបណ្តាប្រទេសអាហ្វ្រិក(ASP)។

ក្រុមទាំងឡាយនៅក្នុងកម្មវិធីASP មានគំនិតខុសៗគ្នាអំពីវិធីសម្អាតកាកសំណល់។ អ្នកខ្លះនិយាយថា វិធីដែលងាយបំផុត និងចំណាយតិចបំផុត គឺត្រូវដុតវាចោល។ ធនាគារពិភពលោក និងរដ្ឋាភិបាលមួយចំនួន កំពុងសាងសង់ឡសម្រាប់ដុតកាកសំណល់ទាំងនេះ។ ក្រុមដទៃទៀតនៅក្នុងកម្មវិធីASP និយាយថា ការដុតកាកសំណល់ទាំងនេះនឹងបញ្ចេញធាតុពុលទៅក្នុងខ្យល់និងទឹក ហើយក៏បានលើកឡើងនូវមធ្យោបាយផ្សេងៗទៀត។ រហូតមកទល់ពេលនេះ គ្មានវិធីសុវត្ថិភាពពិតប្រាកដក្នុងការបំផ្លាញសារធាតុគីមីទាំងនេះទេ។ ការបង្កើតមធ្យោបាយសុវត្ថិភាព នឹងត្រូវចំណាយច្រើនជាងការដុត ហើយនឹងចំណាយពេលយូរ។



ខណៈដែលកម្មវិធីASP ធ្វើការងារដើម្បីដោះស្រាយបញ្ហានេះ កាកសំណល់ពុលបានហើរទៅក្នុងខ្យល់ និងជ្រាបទៅក្នុងទឹកក្រោមដី។ ការបំពុលនិងជំងឺផ្សេងៗដែលកាកសំណល់បង្កឡើង គឺជាផ្នែកមួយនៃកេរដំណែលគ្រោះថ្នាក់ដល់ជីវិត ដែលក្រុមហ៊ុនគីមីនិងភ្នាក់ងារអភិវឌ្ឍន៍បានផលិតនិងលើកកម្ពស់ការប្រើប្រាស់វា។

# ការកែច្នៃអាគុយ/ថ្មពិល

អាគុយជាតិសំណដែលយកពីរថយន្ត ជាញឹកញាប់ត្រូវបានកែច្នៃយកជាតិលោហៈដែលមានក្នុងនោះ។ នៅកន្លែងភាគច្រើន វាមិនមែនជាដំណើរការឧស្សាហកម្មទេ ប៉ុន្តែវាត្រូវបានធ្វើនៅក្នុងផ្ទះនិងក្រោយផ្ទះ។ ការកែច្នៃអាគុយ បង្កើតការបំពុលដោយជាតិសំណយ៉ាងធ្ងន់ធ្ងរ ដែលបំផ្លាញដល់សុខភាពមនុស្សនិងបរិស្ថាន។ ការប្រឈមនឹងជាតិសំណកម្រិតខ្ពស់ក្នុងរយៈពេលខ្លី អាចបណ្តាលឲ្យក្អួត រាក ប្រកាច់ សន្លប់យូរ ឬថែមទាំងស្លាប់ទៀតផង(មើលទំព័រ368ទៅ370)។

នៅកន្លែងខ្លះ ថ្មពិលតូចៗត្រូវបានគេផ្តាច់ចេញពីគ្នា ដើម្បីយកម្សៅពណ៌ខ្មៅនៅខាងក្នុងធ្វើជាថ្នាំជ្រលក់ពណ៌ ថ្នាំពណ៌ និងផលិតផលសម្អាង។ ម្សៅនេះមានជាតិពុលខ្លាំងណាស់ និងមិនគួរយកមកប្រើក្នុងគោលបំណងទាំងនេះឡើយ។ វាត្រូវបានផលិតចេញពីកាតមីញ៉ូម សំណ ស័ង្កសី បារត និងលោហៈធ្ងន់ពុលផ្សេងទៀត។ ប្រសិនបើប្រើម្សៅនេះ ត្រូវតែរៀបចំវាដោយពាក់ស្រោមដៃនិងម៉ាស់ ហើយបោះចោលវាឲ្យមានសុវត្ថិភាព។

### ការកាត់បន្ថយគ្រោះថ្នាក់

វិធីល្អបំផុតក្នុងការកាត់បន្ថយការប្រឈមនឹងសារធាតុពុលក្នុងអាគុយនិងថ្មពិល គឺត្រូវឲ្យអ្នកផលិតរបស់ទាំងនេះជាអ្នកប្រមូលអាគុយនិងថ្មពិលដែលប្រើរួច ហើយប្រាកដថាវាត្រូវបានកែច្នៃដោយស្ថិតក្នុងស្ថានភាពសុវត្ថិភាព។ ប្រទេសខ្លះមានច្បាប់ដាក់កម្រិតលើការកែច្នៃអាគុយនិងថ្មពិលដោយសុវត្ថិភាព។

# ការកែច្នៃឧបករណ៍អេឡិចត្រូនិច

ការបង្កើតឧបករណ៍អេឡិចត្រូនិច ដូចជាកុំព្យូទ័រ ទូរទស្សន៍ ទូរស័ព្ទដៃ និងវិទ្យុ ទាមទារធនធានយ៉ាងច្រើន។ ឧបករណ៍អេឡិចត្រូនិចក៏ផ្ទុកសារធាតុពុលជាច្រើនផងដែរ ដូចជាសំណ កាតមីញ៉ូម បារីយ៉ូម បារត សារធាតុពន្យឺតអណ្តាតភ្លើង(មើលទំព័រ372) PCBs(មើលទំព័រ372) និងប្លាស្ទិកPVC(មើលទំព័រ341)។

ជាញឹកញាប់ ឧបករណ៍អេឡិចត្រូនិចត្រូវបានបោះចោលនៅក្នុងរណ្តៅសំរាមដែលសារធាតុពុលនៅក្នុងនោះ ជ្រាបចូលទៅក្នុងទឹកក្រោមដី។ ឬមួយវាត្រូវបានបំបែកចេញពីគ្នា ហើយសារធាតុដែលមានក្នុងនោះត្រូវបានកែច្នៃឡើងវិញ(ដែលច្រើនតែធ្វើដោយដៃ)ដោយប្រើសារធាតុរំលាយ។ បែបនេះបង្កបញ្ហាសុខភាពធ្ងន់ធ្ងរដល់មនុស្សដែលធ្វើការងារកែច្នៃ និងយកសារធាតុពុលទៅបញ្ចូលក្នុងផលិតផលដទៃទៀតដែលនឹងធ្វើឲ្យមានបញ្ហាសុខភាពនៅថ្ងៃក្រោយ។

ដំណោះស្រាយសុវត្ថិភាពបំផុត គឺត្រូវតម្រូវឲ្យក្រុមហ៊ុនដែលផលិតឧបករណ៍អេឡិចត្រូនិច ទទួលខុសត្រូវលើការកែច្នៃឡើងវិញដោយសុវត្ថិភាព និងរៀបចំបង្កើតឡើងវិញនូវផលិតផលដែលប្រើប្រាស់សារធាតុគ្រោះថ្នាក់តិចតួច និងដែលប្រើបានយូរ។ ចំណែកឯប្រជាជនដែលទិញនិងប្រើប្រាស់ផលិផលអេឡិចត្រូនិក អាចកាត់បន្ថយកាកសំណល់គ្រោះថ្នាក់ ដោយយកវាទៅជួសជុលនៅពេលខូច ជាជាងបោះវាចោល។



ការពាក់ម៉ាស់ ស្រោមដៃ និងឧបករណ៍ការពារដទៃទៀត នឹងជួយការពារប្រជាជនដែលធ្វើការងារកែច្នៃគ្រឿងកុំព្យូទ័រ។

# ពាណិជ្ជកម្មកាកសំណល់ពុល

ពាណិជ្ជកម្មកាកសំណល់ពុលគឺជាការនាំចេញពីប្រទេសមួយទៅប្រទេសមួយ នូវកាកសំណល់ពុល និងសារធាតុគ្រោះថ្នាក់។ ដោយសារប្រទេសអ្នកមានច្រើនតែព្យាយាមចាក់កាកសំណល់របស់ខ្លួនទៅឲ្យឆ្ងាយ ហើយដោយសាររដ្ឋាភិបាលនៃប្រទេសក្រីក្រ មិនសូវមានអំណាចក្នុងការបញ្ឈប់វា, ទើបពាណិជ្ជកម្មកាកសំណល់ពុលភាគច្រើនបំផុតមានន័យថា ប្រទេសអ្នកមាននិងសហគមន៍អ្នកមាន ចាក់កាកសំណល់ទៅក្នុងប្រទេសក្រីក្រនិងសហគមន៍ក្រីក្រ។

ទោះបីមានកិច្ចព្រមព្រៀងជាអន្តរជាតិស្តីពីការការពារសុខភាពនិងបរិស្ថានក៏ដោយ ពាណិជ្ជកម្មកាកសំណល់ពុល គឺជាផ្នែកមួយនៃពាណិជ្ជកម្មសកល។ ទោះបីវាមានគ្រោះថ្នាក់ក្តី ផលិតផលផ្សេងៗដូចជាថ្នាំជក់ ថ្នាំសម្លាប់សត្វល្អិត អាហារបង្អាត់ពូជ អាបែសស្តូ ឧស្ម័នសំណ ឧបករណ៍អេឡិចត្រូនិចចាស់ៗ និងវត្ថុដទៃទៀត ជាញឹកញាប់ត្រូវបានបញ្ជូនពីប្រទេសអ្នកមានទៅប្រទេសក្រីក្រ។

ពាណិជ្ជកម្មកាកសំណល់ពុលខ្លះត្រូវបានហាមឃាត់ដោយច្បាប់អន្តរជាតិ(មើលទំព័រ467)។ ប៉ុន្តែដូចសកម្មជនផ្នែកសុខភាពនិងសិទ្ធិមនុស្សជាច្រើន បានដឹងរួចហើយថា ច្បាប់អាចការពារប្រជាជនតែនៅពេលដែលប្រជាជនរៀបចំសកម្មភាពទាមទារឲ្យមានការអនុវត្តច្បាប់ប៉ុណ្ណោះ។

## យកកាកសំណល់ពុលរបស់អ្នក ទៅផ្ទះវិញទៅ

ឃានស៊ី គឺជាកប៉ាល់មួយដែលផ្ទុកទៅដោយផេះពុលចេញពីឡសំរាម ចំនួន១៤.០០០តោន មកពីទីក្រុងហ្វីឡាដែលហ្វៀ នៃសហរដ្ឋអាមេរិក ដើម្បីយកទៅចាក់ចោលនៅទីណាផ្សេងក្រៅពីសហរដ្ឋអាមេរិក។ ប៉ុន្តែទោះបីកប៉ាល់នេះទៅទីណា ក៏ប្រជាជនបដិសេធមិនទទួលយកដែរ។ ដំបូង កប៉ាល់នេះធ្វើដំណើរទៅប្រទេសបាហាម៉ា បន្ទាប់មកទៅសាធារណរដ្ឋដូមីនិកកាំង ប៉ុន្តែប្រទេសទាំងពីរមិនទទួលយកកាកសំណល់នេះទេ។ គេបន្តដំណើរទៅប្រទេសហុងឌូរ៉ាស់, ប៊ឺមូដា, ហ្គីនីប៊ីសាវ និងប្រទេសនីឌ័រលែនអាន់ធីលី។ ប៉ុន្តែគ្មានប្រទេសណាមួយចង់បានផេះពុលនេះទេ។

ដោយអស់សង្ឃឹមនឹងការចាក់ផេះពុលនេះ ក្រុមនាវិកបានកុហកពីកប៉ាល់នេះ។ ជួនកាលពួកគេនិយាយថា ផេះពុលនេះគឺជាសម្ភារៈសំណង់ ឬសម្ភារៈសម្រាប់ចាក់បំពេញផ្លូវ។ ប៉ុន្តែពួកសកម្មជនផ្នែកបរិស្ថាន បានដើរមុនកប៉ាល់មួយជំហានរួចហើយ ដោយបានប្រាប់ប្រទេសទាំងឡាយឲ្យដឹងថាតើអ្វីពិតប្រាកដដែលមាននៅក្នុងផេះនោះ។ គ្មាននរណាម្នាក់ទទួលយកវាទេ រហូតទាល់តែទៅដល់ប្រទេសហៃទី។ នៅទីនោះ រដ្ឋាភិបាលហៃទីដែលមានអាមេរិកជាអ្នកគាំទ្រ បានអនុញ្ញាតឲ្យផេះ(ឥឡូវត្រូវបានហៅថា "ជី") នេះចូលក្នុងប្រទេសរបស់ខ្លួន។ ផេះចំនួន៤០០០តោនត្រូវបានចាក់ទៅលើឆ្នេរខ្សាច់មួយនៅក្នុងក្រុងហ្គោណាយ នៃប្រទេសហៃទី។

មុនយូរប៉ុន្មាន ការប្រឆាំងជំទាស់ជាសាធារណៈ បានបង្ខំឲ្យមន្ត្រីហៃទី សារភាពថាវាមិនមែនជាជីទេ។ ពួកគេបញ្ជាឲ្យយកកាកសំណល់នោះទៅកប៉ាល់វិញ។ ប៉ុន្តែកប៉ាលនេះបានគេចទៅឆ្ងាយតាំងពីយប់ម្ល៉េះ។

ក្នុងរយៈពេល២ឆ្នាំ កប៉ាល់ឃានស៊ីបានធ្វើដំណើរពីប្រទេសមួយទៅប្រទេសមួយ ព្យាយាមចាក់ចោលផេះដែលនៅដល់១០.០០០តោនទៀត។ ក្រុមនាវិកត្រូវបានបញ្ជាឲ្យលាបពណ៌ប្តូរឈ្មោះកប៉ាល់។ ប៉ុន្តែនៅតែគ្មានប្រទេសណាចាញ់បោកពួកគេដែរ។ ក្រោយមកទៀត នាវិកម្នាក់បានធ្វើសាក្សីក្នុងតុលាការថាភាគច្រើននៃកាកសំណល់ត្រូវបានចាក់ចូលទៅក្នុងសមុទ្រឥណ្ឌា។ នៅចុងបញ្ចប់ ផេះ២០០០តោនត្រូវបានជញ្ជូនត្រឡប់ទៅចាក់ក្នុងរណ្តៅក្នុងក្រុងហ្វីឡាដែលហ្វៀវិញ។ លទ្ធផលនេះគួរតែអរគុណដល់ការខំប្រឹងប្រែងជាច្រើនឆ្នាំរបស់សកម្មជនផ្នែកបរិស្ថាន។

# ការសាងសង់ក្នុងទីក្រុង អាចគាស់កកាយកាកសំណល់ពុល

ជាអកុសល ការព្រងើយកន្តើយនឹងកាកសំណល់ពុល មិនធ្វើឲ្យវាបាត់ទៅណាទេ។ នៅពេលគម្រោងអភិវឌ្ឍន៍ថ្មីៗចាប់ផ្តើមក្នុងទីក្រុង ជាទូទៅប្រជាជនមានការសប្បាយចិត្តនឹងផ្សារថ្មីៗ លំនៅដ្ឋាន ទីកំសាន្ត និងការងារដែលបានបង្កើតសម្រាប់ប្រជាជន។ ប៉ុន្តែនៅពេលគម្រោងទាំងនេះត្រូវបានសាងសង់នៅលើទីកន្លែងដែលធ្លាប់សង់រោងចក្រឬមូលដ្ឋានយោធា នោះប្រជាជនត្រូវតែប្រុងប្រយ័ត្នថា ដីនៅទីនោះមិនមែនធ្លាប់ជាកន្លែងចាក់កាកសំណល់ពុលទេ។ ហើយប្រសិនបើវាធ្លាប់ជាកន្លែងចាក់កាកសំណល់ពុលមែន វាត្រូវតែបានចាក់ដោយសុវត្ថិភាព។

## កីឡាបេសបលដើម្បីសុខភាព




នៅពេលទីក្រុងសែនឌីអ៊ីហ្គោ នៃសហរដ្ឋអាមេរិក ចាប់ផ្តើមសាងសង់ស្តាតថ្មី អ្នកគាំទ្រក្រុមបេសបល( baseball ) San Diego Padres មានភាពរីករាយជាខ្លាំង។ ស្តាតថ្មីនេះនឹងធ្វើឲ្យអាចទស្សនាកីឡាបេសបលបានកាន់តែស្រួល ហើយការសាងសង់ស្តាតនឹងបង្កើតការងារសម្រាប់សហគមន៍។ ប៉ុន្តែការវាយតម្លៃផលប៉ះពាល់លើបរិស្ថាន( EIA ) បានបង្ហាញថា គម្រោងនេះនឹងមានផលប៉ះពាល់យ៉ាងអាក្រក់មកលើបរិស្ថាននិងសុខភាពមនុស្ស។

ទីតាំងដែលបានស្នើសុំសង់ស្តាតនេះ មានភាពកខ្វក់ដោយសារសារធាតុគីមីពុល។ គម្រោងនេះបានស្នើសុំឲ្យជីកស្រទាប់ដីពុល រួចដុតវានៅកណ្តាលទីក្រុងតែម្តង។ សមាជិកនៃក្រុមសហពលកម្មដើម្បីសុខភាពបរិស្ថាន( EHC ) ដឹងថាបែបនេះនឹងបង្កបញ្ហាសុខភាពយ៉ាងធ្ងន់ធ្ងរ។ ដូច្នេះពួកគេក៏បានរៀបចំសកម្មភាពដើម្បីឲ្យសហគមន៍ទាមទារមធ្យោបាយជំនួសវិញ។

ក្រុមEHC និងសមាជិកសហគមន៍បានស្នើសុំឲ្យមន្ត្រីក្រុងបដិសេធគម្រោងដុតដីកខ្វក់ ប៉ុន្តែក្រុងបានបដិសេធសំណើរនេះ។ បន្ទាប់មកសហគមន៍បានប្រមូលអ្នករស់នៅជាង១០០នាក់ មកតវ៉ានៅលើផ្លូវនៃទីតាំងសំណង់។ នៅពេលប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក រាយការណ៍ពីបញ្ហានេះ ក្រុមកីឡា San Diego Padres ហាក់ដូចជាមិនយកចិត្តទុកដាក់នឹងអ្នកគាំទ្ររបស់ខ្លួនទេ។ មិនយូរប៉ុន្មាន ម្ចាស់ក្រុមកីឡានេះបានយល់ព្រមស្វែងរកមធ្យោបាយផ្សេងដើម្បីដោះស្រាយស្រទាប់ដីពុលនេះ។

ក្រុមEHC ក៏បានបង្ហាញពីរបៀបដែលស្តាតថ្មីនឹងបង្កការស្ទះចរាចរ ការបំពុលខ្យល់ និងជំងឺហឺតក្នុងចំណោមកុមារនៅជុំវិញតំបន់នេះផងដែរ។ បន្ទាប់ពីការប្រជុំជាច្រើនដង ក្រុមEHCបានជួយបង្កើតផែនការសាងសង់ថ្មីដែលមិនសូវប៉ះពាល់សុខភាព។

ទោះបីមានការប្រជុំជាសាធារណៈ និងមានការវាយតម្លៃផលប៉ះពាល់លើបរិស្ថានក៏ដោយ ក៏មិនមែនមានន័យថាគម្រោងមួយនឹងមិនបង្កគ្រោះថ្នាក់ដែរ។ ដូចក្នុងករណីស្តាតសែនឌីអ៊ីហ្គោ នេះជាដើម អ្នកអភិវឌ្ឍន៍ចេះតែចង់ចាប់ផ្តើមគម្រោងរបស់ខ្លួន ទោះបីបានដឹងពីគ្រោះថ្នាក់នៃការដុតស្រទាប់ដីពុល និងបញ្ហាផ្សេងៗទៀតចេញពីផែនការស្តាតនេះហើយក៏ដោយ។ បន្ទាប់ពីមានក្រុមប្រជាជនដែលមានការប្តេជ្ញាចិត្តខ្ពស់ បានធ្វើការសិក្សាលើរបាយការណ៍ ចូលរួមការប្រជុំ និងតវ៉ាប្រឆាំងនៅតាមផ្លូវ ទើបរដ្ឋាភិបាលព្រមកាត់បន្ថយគ្រោះថ្នាក់។ មនុស្សជាច្រើននៅសែនឌីអ៊ីហ្គោយកចិត្តទុកដាក់លើការលេងរបស់ក្រុមPadres រៀងរាល់ពេលប្រកួត។ ឥឡូវនេះពួកគេអាចគាំទ្រក្រុមរបស់ខ្លួន និងដឹងថាវាមិនទាន់ធ្វើឲ្យពួកគេមានជំងឺនៅឡើយទេ។

## កិច្ចព្រមព្រៀងអន្តរជាតិស្តីអំពីការបោះចោលកាកសំណល់ពុល

ជាច្រើនឆ្នាំកន្លងទៅ ពួកប្រទេសអ្នកមាននៅទ្វីបអាមេរិកខាងជើង និងអឺរ៉ុប បានប្រើប្រាស់ទ្វីបអាហ្វ្រិក អាស៊ី អាមេរិកឡាទីន និងអឺរ៉ុបខាងកើត ធ្វើជាកន្លែងចាក់កាកសំណល់របស់ខ្លួន ដោយមិនមានសម្ពាធផ្លូវច្បាប់ណាមួយបញ្ឈប់ពួកគេឡើយ។ នៅចុងក្រោយ សកម្មភាពក្នុងសហគមន៍នៃប្រទេសក្រីក្រ រួមជាមួយនឹងសម្ពាធពីអ្នកបរិស្ថាននៅទូទាំងពិភពលោក បានឈ្នះកិច្ចព្រមព្រៀងអន្តរជាតិមួយដែលចាត់ទុកពាណិជ្ជកម្មកាកសំណល់ពុលថាខុសច្បាប់។

កិច្ចព្រមព្រៀងដំបូងគឺ អនុសញ្ញាក្រុងបាហ្សែល ស្តីអំពីការគ្រប់គ្រងចលនាឆ្លងប្រទេសនៃកាកសំណល់ឆ្លងរោគនិងការបោះចោលវា(ឆ្នាំ១៩៩២)។ កិច្ចព្រមព្រៀងបានឈ្នះភាគច្រើនគឺដោយសារសកម្មជនទាំងឡាយដែលតាមដានកប៉ាល់យានស៊ីដែលធ្វើដំណើរជុំវិញពិភពលោកដើម្បីព្យាយាមចាក់ចោលផេះពុលរបស់ខ្លួន។ បណ្តាប្រទេសដែលចុះហត្ថលេខាលើអនុសញ្ញាក្រុងបាហ្សែល យល់ព្រមថានឹងរម្ងាប់មេរោគ ប្រើប្រាស់ឡើងវិញ និងបោះចោលកាកសំណល់ពុលឲ្យនៅជិតបំផុតពីកន្លែងដែលបង្កើតវាចេញមក ជាជាងដឹកជញ្ជូនយកទៅចាក់ចោលនៅប្រទេសដទៃ។

នៅឆ្នាំ២០០១ ប្រទេសចំនួន៩២ បានចុះហត្ថលេខាលើអនុសញ្ញាក្រុងស្តុកខុម ស្តីអំពីPOP( សារធាតុសរីរាង្គពុលអូសបន្លាយ, មើលទំព័រ340)។ អនុសញ្ញានេះហាមឃាត់ការផលិតនិងការប្រើប្រាស់POPដែលគ្រោះថ្នាក់បំផុតចំនួន១២មុខ (ហៅថា "វត្ថុកខ្វក់ទាំង១២") ហើយចាត់ទុកការធ្វើពាណិជ្ជកម្មPOPទាំងនេះជាការខុសច្បាប់ លើកលែងតែការប្រើប្រាស់សារធាតុគីមីពុលជាក់លាក់ណាមួយនឹងបង្ការគ្រោះថ្នាក់បានច្រើនជាងអ្វីដែលវាបង្កឡើង (ដូចជាការប្រើDDTដើម្បីគ្រប់គ្រងជំងឺគ្រុនចាញ់, មើលទំព័រ150)។

កិច្ចព្រមព្រៀងលើកទី៣ត្រូវបានអនុម័តនៅឆ្នាំ២០០៤ គឺអនុសញ្ញាក្រុងរ៉ុតធីដាំ ស្តីអំពីការអនុញ្ញាតជាមុន។ អនុសញ្ញានេះតម្រូវឲ្យប្រទេសមួយជូនដំណឹងនិងទទួលការអនុញ្ញាតពីប្រទេសមួយទៀតសិនមុននឹងនាំចេញសារធាតុគីមីគ្រោះថ្នាក់ទៅប្រទេសនោះ។

នៅពេលប្រជាជនដឹងអំពី និងប្រើប្រាស់កិច្ចព្រមព្រៀងទាំងនេះ នោះវាក្លាយជាឧបករណ៍សំខាន់មួយដើម្បីធ្វើឲ្យពិភពលោករបស់យើងមានសុខភាពប្រសើរនិងកាន់តែមានយុត្តិធម៌។ ប៉ុន្តែមានវិធីជាច្រើនដែលប្រទេសនិងសាជីវកម្មទាំងនោះអាចគេចវេះពីច្បាប់បាន។ សម្រាប់ព័ត៌មានបន្ថែមអំពីវិធីប្រើប្រាស់ច្បាប់ទាំងនេះ និងច្បាប់ជាតិនិងអន្តរជាតិដទៃទៀត ក្នុងការតស៊ូដើម្បីសុខភាពបរិស្ថានរបស់អ្នក សូមមើលសេចក្តីបន្ថែម ខ។



## ល្បែងពស់ និងជណ្ដើរ



ល្បែងពស់និងជណ្ដើរគឺជាល្បែងលើក្ដារមួយដ៏មានប្រជាប្រិយនៅក្នុងការអប់រំអំពីសុខភាព។ ល្បែងក្នុងទំព័រនេះអាចបង្ហាញពីរបៀបផ្សេងៗដែលសារធាតុពុលបង្កគ្រោះថ្នាក់មកលើយើង និងពីរបៀបបង្ការនិងកាត់បន្ថយគ្រោះថ្នាក់។ អ្នកអាចបង្កើតល្បែងនេះដោយខ្លួនឯង ដោយចម្លងតាមវាខាងក្រោម ទៅលើផ្ទាំងក្រដាសធំ ក្រដាសឡាំង ឬបន្ទះក្ដារ។

**សម្ភារៈ :** គ្រាប់ឡុកឡាក់, និងគ្រាប់ពូជ ដុំថ្ម ឬសម្បកលៀស ដើម្បីធ្វើគ្រាប់ដើរ, និងបន្ទះក្ដារ១។

**ក្បួន :** ល្បែងនេះអាចលេងបានចំពោះមនុស្សពី២ទៅ៤នាក់ ឬលេងជាក្រុមៗ។ អ្នកលេងម្នាក់ៗមានគ្រាប់ដើរមួយ(គ្រាប់ពូជ ដុំថ្ម ឬសម្បកលៀស) ដើម្បីបង្ហាញពីទីតាំងដែលគាត់ស្ថិតនៅលើបន្ទះក្ដារ។




អ្នកលេងទី១បោះគ្រាប់ឡុកឡាក់ រួចដើរគ្រាប់របស់គាត់តាមលេខដែលបោះបាន ដោយចាប់ផ្ដើមពីក្រឡាការេទី១ដែលមានសរសេរថា "ចាប់ផ្ដើម"។

ប្រសិនបើបោះគ្រាប់ឡុកឡាក់បានលេខ៦ នោះគាត់ដើរបាន៦ក្រឡា រួចអាចបោះបានម្ដងទៀត។ បើខុសពីលេខ៦ អ្នកលេងបន្ទាប់ត្រូវបោះម្ដង។

ប្រសិនបើគ្រាប់ដើរត្រូវក្រឡាដែលមានរូបក្បាលពស់ នោះអ្នកលេងម្នាក់នេះត្រូវអានអក្សរក្នុងប្រឡោះនោះឲ្យឮ បន្ទាប់មកលើកគ្រាប់ដើរទៅត្រង់កន្ទុយពស់វិញ ហើយអានអក្សរនៅលើប្រអប់កន្ទុយពស់នេះ។ អ្នកត្រូវចាប់ផ្ដើមពីក្រឡានេះឡើងវិញ។




ប្រសិនបើដើរចំជើងជណ្ដើរ ត្រូវអានអក្សរនៅប្រឡោះនោះឲ្យឮ បន្ទាប់លើកគ្រាប់ដើរទៅចុងជណ្ដើរ ហើយអានអក្សរនៅប្រឡោះចុងជណ្ដើរ។ អ្នកត្រូវចាប់ផ្ដើមពីក្រឡានេះឡើងវិញ។

អ្នកណាដែលដើរដល់ក្រឡាចុងក្រោយគេ គឺជាអ្នកឈ្នះ។ អ្នកលេងត្រូវតែបោះគ្រាប់ឡុកឡាក់រហូតទាល់តែបានលេខដែលត្រូវការដើម្បីដើរទៅក្រឡាចុងក្រោយ។

ល្បែងនេះមានប្រសិទ្ធភាពបំផុតនៅពេលអ្នកកែតម្រូវព័ត៌មាននៅក្នុងក្រឡាពស់ ឲ្យត្រូវនឹងបញ្ហាសុខភាពនិងសារធាតុពុលដែលមាននៅក្នុងសហគមន៍របស់អ្នក។ ដូចគ្នាដែរ គួរកែតម្រូវព័ត៌មាននៅក្នុងក្រឡាជណ្ដើរទៅជាសកម្មភាពនានាដើម្បីកាត់បន្ថយការប្រឈមសារធាតុពុល និងដំណោះស្រាយផ្សេងៗដែលពាក់ព័ន្ធនឹងសហគមន៍របស់អ្នក។

ជំរុញឲ្យអ្នកលេងទាំងអស់ ពិភាក្សាអំពីបញ្ហា(ពស់)និងដំណោះស្រាយ(ជណ្ដើរ)ទាំងឡាយក្នុងពេលលេងល្បែងនេះ។ នៅពេលចប់ សួរពួកគេថាតើមានបញ្ហាសារធាតុពុលផ្សេងទៀតដែលមិនបានលើកឡើងនៅក្នុងល្បែងដែរឬទេ ហើយបើមាន តើសកម្មភាពអ្វីខ្លះដែលប្រជាជនអាចធ្វើបាន ដើម្បីការពារសុខភាពរបស់ខ្លួន។






សម្រាប់ព័ត៌មានបន្ថែមអំពីការបង្កើតនិង ប្រើប្រាស់ល្បែងបន្ទះក្តារ សូមមើលជំពូក11 នៃសៀវភៅ *ការជួយបុគ្គលិកសុខាភិបាល ឲ្យរៀនសូត្រ* របស់អង្គការហេស្ពើរៀន។